N-25
08.7-02

# ក

## មាតិកា

## I- ខុទ្ទកាល័យព្រះមហាក្សត្រ

### ព្រះរាជក្រឹត្យ


| | | |
|---|---|---|
| ១៩-៦-២០០២ | - ព្រះរាជក្រឹត្យ នស/រកត/០៦០២/១៩៧ ស្តីពីការផ្ទេរភារកិច្ចចៅក្រមក្រសួងយុត្តិធម៌ ចៅក្រមតុលាការក្រុងភ្នំពេញ ព្រះរាជអាជ្ញាអមតុលាការខេត្តព្រៃវែង និងចៅក្រមតុលាការខេត្តស្ទឹងត្រែង | ១៨១៤ |


## II-រាជរដ្ឋាភិបាល

### ១- អនុក្រឹត្យ


| | | |
|---|---|---|
| ០១-៧-២០០២ | -អនុក្រឹត្យ លេខ ៦៣ អនក្រ .បក ស្តីពីការផ្ទេរឥណទានថវិកា | ១៨១៦ |
| ០១-៧-២០០២ | -អនុក្រឹត្យ លេខ ៦៤ អនក្រ .បក ស្តីពីការផ្ទេរឥណទានថវិកា | ១៨១៨ |
| ០៤-៧-២០០២ | -អនុក្រឹត្យ លេខ ៦៥ អនក្រ .បក ស្តីពីការផ្ទេរឥណទានថវិកា | ១៨២០ |
| ០១-៧-២០០២ | -អនុក្រឹត្យ លេខ ៣១៩ អនក្រ.តត ស្តីពីការតែងតាំងក្រុមប្រឹក្សាភិបាល សំរាប់ដឹកនាំវិទ្យាស្ថាន ស្រាវជ្រាវចំការកៅស៊ូកម្ពុជា | ១៨២២ |
| ០២-៧-២០០២ | -អនុក្រឹត្យ លេខ ៣២០ អនក្រ.តត ស្តីពីការជូនមេដាយការងារ | ១៨២៤ |
| ០២-៧-២០០២ | -អនុក្រឹត្យ លេខ ៣២១ អនក្រ.តត ស្តីពីការតែងតាំងមន្ត្រីរាជការ | ១៨២៥ |
| ០២-៧-២០០២ | -អនុក្រឹត្យ លេខ ៣២២ អនក្រ.តត ស្តីពីការតែងតាំងបេសកជន | ១៨២៧ |
| ០៤-៧-២០០២ | -អនុក្រឹត្យ លេខ ៣២៣ អនក្រ.តត ស្តីពីការតម្លើងឋានន្តរសក្តិនាយនគរបាលជាតិ | ១៨២៨ |
| ០៤-៧-២០០២ | -អនុក្រឹត្យ លេខ ៣២៤ អនក្រ.តត ស្តីពីការតម្លើងឋានន្តរសក្តិនាយនគរបាលជាតិ ជាកិច្ចបច្ឆាមរណៈ | ១៨២៩ |
| ០៤-៧-២០០២ | -អនុក្រឹត្យ លេខ ៣២៥ អនក្រ.តត ស្តីពីការតែងតាំងសមាជិកក្រុមប្រឹក្សាភិបាល អាណត្តិទី ២ នៃរដ្ឋាករទឹកស្វយ័តក្រុងភ្នំពេញ | ១៨៣០ |
| ០៥-៧-២០០២ | -អនុក្រឹត្យ លេខ ៣២៦ អនក្រ.តត ស្តីពីការតែងតាំងសមាជិកក្រុមប្រឹក្សាភិបាល នៃគ្រឹះស្ថានបោះពុម្ពនិងចែកផ្សាយ | ១៨៣១ |
| ០៨-៧-២០០២ | -អនុក្រឹត្យ លេខ ៣២៧ អនក្រ.តត ស្តីពីការជូនមេដាយស្ថាបនាជាតិ | ១៨៣៣ |
| ០៨-៧-២០០២ | -អនុក្រឹត្យ លេខ ៣២៨ អនក្រ.តត ស្តីពីការជូនមេដាយស្ថាបនាជាតិ | ១៨៣៤ |
| ០៨-៧-២០០២ | -អនុក្រឹត្យ លេខ ៣២៩ អនក្រ.តត ស្តីពីការជូនមេដាយស្ថាបនាជាតិ | ១៨៣៦ |
| ០៨-៧-២០០២ | -អនុក្រឹត្យ លេខ ៣៣០ អនក្រ.តត ស្តីពីការជូនមេដាយស្ថាបនាជាតិ | ១៨៣៧ |
| ០៨-៧-២០០២ | -អនុក្រឹត្យ លេខ ៣៣១ អនក្រ.តត ស្តីពីការជូនមេដាយស្ថាបនាជាតិ | ១៨៣៨ |

25




០៨-៧-២០០២ -អនុក្រឹត្យ លេខ ៣៣២ អនក្រ.តត ស្តីពីការជូនមេដាយស្ថាបនាជាតិ ១៨៣៩

**២.សេចក្តីសំរេច**

២៨-៦-២០០២ -សេចក្តីសំរេចលេខ ៣៦ សសរ ស្តីពីការបន្ថែមសមាសភាព ក្នុងក្រុមការងារ ដើម្បីរៀបចំឯកសារគតិយុត្តិ និងពិនិត្យដោះស្រាយចំពោះគំរោងជួល និងអភិវឌ្ឍន៍ កោះរុង និងកោះរុងសន្លឹម របស់ក្រុមហ៊ុន **ISLAND DEVELOPMENT GROUP INC.** ១៨៤០

០៨-៧-២០០២ -សេចក្តីសំរេចលេខ ៣៧ សសរ ស្តីពីការបន្ថែមសមាសភាព ក្នុងក្រុមការងារ ដើម្បីរៀបចំឯកសារគតិយុត្តិ និងពិនិត្យដោះស្រាយចំពោះគំរោងជួល និងអភិវឌ្ឍន៍កោះរុង និងកោះរុងសន្លឹម របស់ក្រុមហ៊ុន **ISLAND DEVELOPMENT GROUP INC.** ១៨៤២

**៣.សារាចរណែនាំ**

០៥-៧-២០០២ - សារាចរណែនាំស្តីពីការប្រារព្ធទិវាអក្ខរកម្មជាតិ ៨ កញ្ញា ១៨៤៤

**II- ការងារបណ្តាក្រសួង**

**១.អន្តរក្រសួងសេដ្ឋកិច្ចនិងហិរញ្ញវត្ថុ និងក្រសួងឧស្សាហកម្មរ៉ែនិងថាមពល**

០១-៧-២០០២ - ប្រកាសលេខ ៤១៤ សហវ ស្តីពីការរំលាយចោលកិច្ចសន្យាជួលរោងចក្រយន្តសាស្ត្រទី ៦ ១៨៤៦

**២.អន្តរក្រសួងសេដ្ឋកិច្ចនិងហិរញ្ញវត្ថុ និងសាលាក្រុងភ្នំពេញ**

០៤-៧-២០០២ -ប្រកាសលេខ ៤១៩ សហវ ស្តីពីការលប់ចោលកិច្ចសន្យា ជួលអតីត រោងភាពយន្តខេមរៈ ១៨៤៨

**៣. ទីស្តីការរដ្ឋមន្ត្រីក្រសួង សេដ្ឋកិច្ច និង ហិរញ្ញវត្ថុ**

០៣-៧-២០០២ -សេចក្តីជូនដំណឹង លេខ ០១៩ សហវ.ពដ ស្តីពីការអនុវត្តន៍ប្រមូលពន្ធលើ មធ្យោបាយដឹកជញ្ជូន និងយានជំនិះគ្រប់ប្រភេទសំរាប់ឆ្នាំ ២០០២ ១៨៥០

**៤.ទីស្តីការរដ្ឋមន្ត្រីក្រសួងសាធារណការ និង ដឹកជញ្ជូន**

០៣-៧-២០០២ -សេចក្តីសំរេច លេខ ២២០ សសរ.សក ស្តីពីការបង្កើតក្រុមការងារសហប្រតិបត្តិការអភិវឌ្ឍន៍តំបន់ត្រីកោណ កម្ពុជា-ឡាវ-វៀតណាម និងកម្ពុជា-ឡាវ-ថៃ ១៨៥១

**៥.ទីស្តីការរដ្ឋមន្ត្រីក្រសួងសង្គមកិច្ច ការងារបណ្តុះបណ្តាលវិជ្ជាជីវៈ និងយុវនីតិសម្បទា**

០៥-៧-២០០២ -សារាចរ លេខ ១២ សកបយ.ស្តីពីការដោះស្រាយវិវាទការងារ ១៨៥៣

# ព្រះរាជក្រឹត្យ

នស/រកត/០៦០២/១៥៧

## យើង

**ព្រះបាទសម្តេចព្រះ នរោត្តម សីហនុ**
**រាជហរិវង្ស ឧភតោសុជាត វិសុទ្ធពង្ស អគ្គមហាបុរសរតន៍**
**និករោត្តម ធម្មិកមហារាជាធិរាជ បរមនាថ បរមបពិត្រ**
**ព្រះចៅក្រុងកម្ពុជាធិបតី**

- បានទ្រង់យល់រដ្ឋធម្មនុញ្ញ នៃព្រះរាជាណាចក្រកម្ពុជា
- បានទ្រង់យល់ព្រះរាជក្រឹត្យលេខ នស/រកត/១១៩៨/៧២ ចុះថ្ងៃទី ៣០ វិច្ឆិកា ឆ្នាំ១៩៩៨ ស្តីពីការតែងតាំងរាជរដ្ឋាភិបាល នៃព្រះរាជាណាចក្រកម្ពុជា
- បានទ្រង់យល់ច្បាប់ស្តីពីការចាត់តាំង និងសកម្មភាពរបស់សាលាជំរះក្តីនៃរដ្ឋកម្ពុជា ដែលប្រកាសឱ្យប្រើដោយក្រឹត្យលេខ ០៦ក្រ ចុះថ្ងៃទី ០៨ ខែកុម្ភៈ ឆ្នាំ ១៩៩៣
- បានទ្រង់យល់ច្បាប់ស្តីពីការរៀបចំ និងការប្រព្រឹត្តទៅ នៃឧត្តមក្រុមប្រឹក្សានៃអង្គចៅក្រម ដែលប្រកាសឱ្យប្រើដោយព្រះរាជក្រមលេខ ០៩/នស/៩៤ ចុះថ្ងៃទី ២២ ខែ ធ្នូ ឆ្នាំ ១៩៩៤
- យោងតាមសេចក្តីក្រាបបង្គំទូលស្នើសុំរបស់រដ្ឋមន្ត្រីក្រសួងយុត្តិធម៌ ដែលបានការឯកភាពពីឧត្តមក្រុមប្រឹក្សានៃអង្គចៅក្រម នាសម័យប្រជុំថ្ងៃទី ២៧ ខែឧសភា ឆ្នាំ ២០០២

## ត្រាស់បង្គាប់

**មាត្រា១** .- ត្រូវបានផ្ទេរភារកិច្ច :

១- លោក **យូរ ឧត្តរា** ចៅក្រមក្រសួងយុត្តិធម៌ ឱ្យមកបំរើការងារជាចៅក្រមនៅតុលាការកំពូល ។

២- លោក **ម៉ុង មុន្នីចរិយា** ចៅក្រមតុលាការក្រុងភ្នំពេញ ឱ្យមកបំរើការងារជាចៅក្រមនៅតុលាការកំពូល ។

៣- លោក **ម៉ែន ពេជ្រសាលី** ព្រះរាជអាជ្ញារងអមតុលាការខេត្តព្រៃវែង ឱ្យមកបំរើការងារជាចៅក្រមនៅក្រសួងយុត្តិធម៌ ។

៤- លោក **សុខ កល្យាណ** ចៅក្រមតុលាការខេត្តស្ទឹងត្រែង ឱ្យមកបំរើការងារជាព្រះរាជអាជ្ញារងអមតុលាការខេត្តព្រៃវែង ។

**មាត្រា២** .- បទបញ្ញត្តិទាំងឡាយណា ដែលមានខ្លឹមសារផ្ទុយនឹងព្រះរាជក្រឹត្យនេះ ត្រូវចាត់ទុកជានិរាករណ៍ ។

មាត្រា៣ .- ឧត្តមក្រុមប្រឹក្សានៃអង្គចៅក្រម និងនាយករដ្ឋមន្ត្រីនៃរាជរដ្ឋាភិបាលកម្ពុជា ត្រូវទទួលបន្ទុកអនុវត្ត ឱ្យបានសំរេចតាមព្រះរាជក្រឹត្យនេះ ។

មាត្រា៤ .- ព្រះរាជក្រឹត្យនេះ ចូលជាធរមានចាប់ពីថ្ងៃឡាយព្រះហស្តលេខានេះតទៅ ។

ព្រះហស្តលេខា និង ព្រះរាជលញ្ឆករ

នរោត្តម សីហនុ

នសរកត.០៦០២.០០១៦៧

ធ្វើនៅព្រះបរមរាជវាំង រាជធានីភ្នំពេញ ថ្ងៃទី ១៩ ខែមិថុនា ឆ្នាំ ២០០២

លេខ : ១៥១ ស.ល

ដើម្បីចម្លងចែក

រាជធានីភ្នំពេញ ថ្ងៃទី ០៤ ខែ កក្កដា ឆ្នាំ២០០២

អគ្គលេខាធិការរាជរដ្ឋាភិបាល

[illegible] ធាន់

# ព្រះរាជាណាចក្រកម្ពុជា

## ជាតិ សាសនា ព្រះមហាក្សត្រ

រាជរដ្ឋាភិបាលកម្ពុជា

លេខ : ៦៣ អនក្រ-បក

# អនុក្រឹត្យ

## ស្តីពីការផ្ទេរឥណទានថវិកា

## រាជរដ្ឋាភិបាល

- បានឃើញរដ្ឋធម្មនុញ្ញនៃព្រះរាជាណាចក្រកម្ពុជា
- បានឃើញព្រះរាជក្រឹត្យលេខ នស/រកត/១១៩៨/៧២ , ចុះថ្ងៃទី ៣០ ខែ វិច្ឆិកា ឆ្នាំ ១៩៩៨ ស្តីពីការតែងតាំងរាជរដ្ឋាភិបាល នៃ ព្រះរាជាណាចក្រកម្ពុជា
- បានឃើញព្រះរាជក្រមលេខ ០២/នស/៩៤ , ចុះថ្ងៃទី ២០ ខែ កក្កដា ឆ្នាំ ១៩៩៤ ដែលប្រកាសអោយប្រើច្បាប់ស្តីពីការរៀបចំ និង ការប្រព្រឹត្តទៅនៃគណៈរដ្ឋមន្ត្រី
- បានឃើញព្រះរាជក្រមលេខ នស/រកម/០១៩៦/១៨ , ចុះថ្ងៃទី ២៤ ខែ មករា ឆ្នាំ ១៩៩៦ ដែលប្រកាសអោយប្រើច្បាប់ស្តីពីការបង្កើតក្រសួងសេដ្ឋកិច្ច និង ហិរញ្ញវត្ថុ
- បានឃើញអនុក្រឹត្យលេខ ០៤ អនក្រ.បក , ចុះថ្ងៃទី ២០ ខែ មករា ឆ្នាំ ២០០០ ស្តីពីការរៀបចំ និង ការប្រព្រឹត្តទៅ នៃ ក្រសួងសេដ្ឋកិច្ច និង ហិរញ្ញវត្ថុ
- បានឃើញព្រះរាជក្រមលេខ ០១/នស/៩៣ ,ចុះថ្ងៃទី ២៨ ខែ ធ្នូ ឆ្នាំ ១៩៩៣ ដែលប្រកាសអោយប្រើច្បាប់ស្តីអំពីប្រព័ន្ធហិរញ្ញវត្ថុ ដែលត្រូវបានកែប្រែដោយច្បាប់ស្តីពីហិរញ្ញវត្ថុ សំរាប់ការគ្រប់គ្រងឆ្នាំ ១៩៩៥ ដែលប្រកាសអោយប្រើដោយព្រះរាជក្រម លេខ ១១/នស/៩៤ , ចុះថ្ងៃទី ៣១ ខែ ធ្នូ ឆ្នាំ ១៩៩៤ និង ត្រូវបានកែប្រែដោយច្បាប់ស្តីពីហិរញ្ញវត្ថុ សំរាប់ការគ្រប់គ្រង ឆ្នាំ ២០០០ ដែលប្រកាសអោយប្រើដោយព្រះរាជក្រមលេខ នស/រកម/១២៩៩/១៥ , ចុះថ្ងៃទី ២៥ ខែ ធ្នូ ឆ្នាំ ១៩៩៩
- បានឃើញព្រះរាជក្រមលេខ នស/រកម/១២០១/១៥ , ចុះថ្ងៃទី ៣១ ខែ ធ្នូ ឆ្នាំ ២០០១ ដែលប្រកាសអោយប្រើច្បាប់ស្តីពីហិរញ្ញវត្ថុ សំរាប់ការគ្រប់គ្រង ឆ្នាំ ២០០២
- បានឃើញអនុក្រឹត្យ លេខ ០៣ អនក្រ.បក , ចុះថ្ងៃទី ០៤ ខែ មករា ឆ្នាំ ២០០២ ស្តីពីការបែងចែកឥណទានថវិកាចំណាយ តាមជំពូក នៃច្បាប់ស្តីពីហិរញ្ញវត្ថុ សំរាប់ការគ្រប់គ្រងឆ្នាំ ២០០២
- បានឃើញអនុក្រឹត្យ លេខ ០៤ អនក្រ.បក , ចុះថ្ងៃទី ០៤ ខែ មករា ឆ្នាំ ២០០២ ស្តីពីការផ្ទេរឥណទានថវិកា
- តាមសំណើរបស់រដ្ឋមន្ត្រីក្រសួងសេដ្ឋកិច្ច និង ហិរញ្ញវត្ថុ

## សំរេច

**មាត្រា១:** ត្រូវបានអនុញ្ញាតអោយផ្ទេរឥណទានថវិកា ចំនួន ៥៧០ លានរៀល ( ប្រាំរយចិតសិបលានរៀល ) ពីជំពូក ១១ ( ចំណាយដំណើរការរដ្ឋបាល សំភារៈ និង ការជួសជុលតូច ) មកជំពូក ៣១ ( អន្តរាគមន៍ក្នុងវិស័យសង្គមកិច្ច និង វប្បធម៌ ) ចំនួន ៥៥៣ លានរៀល ( ប្រាំរយហាសិបបីលានរៀល ) និងជំពូក ៣២ ( អន្តរាគមន៍ក្នុងវិស័យអន្តរជាតិ : វិភាគទានអោយអង្គការអន្តរជាតិនានា ) ចំនួន ១៧ លានរៀល ( ដប់ប្រាំពីរលានរៀលគត់ ) របស់ក្រសួងពាណិជ្ជកម្ម សំរាប់ការគ្រប់គ្រងឆ្នាំ ២០០២ ។

**មាត្រា២:** ការបែងចែកឥណទានថវិកាចំណាយផ្ទៃក្នុងជំពូកទាំងនេះ តាមប្រការ កថាខ័ណ្ឌ និង វាក្យខ័ណ្ឌ ត្រូវធ្វើឡើងដោយប្រកាសរដ្ឋមន្ត្រីក្រសួងសេដ្ឋកិច្ច និង ហិរញ្ញវត្ថុ សំរាប់ រង្វាន់ ៣ % លើចំនួនប្រាក់ចំណូលពិតបានបង់ក្នុងឆ្នាំ ២០០១ និង បង់វិភាគទានជូនអង្គការអន្តរជាតិនានា ឆ្នាំ ២០០២ ។

**មាត្រា៣:** រដ្ឋមន្ត្រីទទួលបន្ទុកទីស្តីការគណៈរដ្ឋមន្ត្រី រដ្ឋមន្ត្រីក្រសួងសេដ្ឋកិច្ច និង ហិរញ្ញវត្ថុ រដ្ឋមន្ត្រីក្រសួងពាណិជ្ជកម្ម ត្រូវទទួលបន្ទុកអនុវត្តអនុក្រឹត្យនេះ ចាប់ពីថ្ងៃចុះហត្ថលេខាតទៅ ។

រាជធានីភ្នំពេញ , ថ្ងៃទី ០៦ ខែ កក្កដា ឆ្នាំ ២០០២

**នាយករដ្ឋមន្ត្រី**

**ហ៊ុន សែន**

**កន្លែងទទួល**

- ក្រសួងព្រះបរមរាជវាំង
- អគ្គលេខាធិការដ្ឋានព្រឹទ្ធសភា
- អគ្គលេខាធិការដ្ឋានរដ្ឋសភា
- ខុទ្ទកាល័យសម្តេចនាយករដ្ឋមន្ត្រី
- ដូចមាត្រា ៣
- កាលប្បវត្តិ - ឯកសារ

**បានយកសេចក្តីជំរាបជូន**

**សម្តេចនាយករដ្ឋមន្ត្រី ដើម្បីចុះហត្ថលេខា**

**គាត ឈន់**

**ទេសរដ្ឋមន្ត្រី**

**រដ្ឋមន្ត្រីក្រសួងសេដ្ឋកិច្ច និង ហិរញ្ញវត្ថុ**

ព្រះរាជាណាចក្រកម្ពុជា

ជាតិ សាសនា ព្រះមហាក្សត្រ

រាជរដ្ឋាភិបាលកម្ពុជា

លេខ : ៦៤ អនក្រ-បក

# អនុក្រឹត្យ

## ស្តីពីការផ្ទេរឥណទានថវិកា

### រាជរដ្ឋាភិបាល

- បានឃើញរដ្ឋធម្មនុញ្ញនៃព្រះរាជាណាចក្រកម្ពុជា
- បានឃើញព្រះរាជក្រឹត្យលេខ នស/រកត/១១៩៨/៧២ , ចុះថ្ងៃទី ៣០ ខែ វិច្ឆិកា ឆ្នាំ ១៩៩៨ ស្តីពីការតែងតាំងរាជរដ្ឋាភិបាល នៃ ព្រះរាជាណាចក្រកម្ពុជា
- បានឃើញព្រះរាជក្រមលេខ ០២/នស/៩៤ , ចុះថ្ងៃទី ២០ ខែ កក្កដា ឆ្នាំ ១៩៩៤ ដែលប្រកាសអោយប្រើច្បាប់ស្តីពីការរៀបចំ និង ការប្រព្រឹត្តទៅនៃគណៈរដ្ឋមន្ត្រី
- បានឃើញព្រះរាជក្រមលេខ នស/រកម/០១៩៦/១៨ , ចុះថ្ងៃទី ២៤ ខែ មករា ឆ្នាំ ១៩៩៦ ដែលប្រកាសអោយប្រើច្បាប់ស្តីពីការបង្កើតក្រសួងសេដ្ឋកិច្ច និង ហិរញ្ញវត្ថុ
- បានឃើញអនុក្រឹត្យលេខ ០៤ អនក្រ.បក , ចុះថ្ងៃទី ២០ ខែ មករា ឆ្នាំ ២០០០ ស្តីពីការរៀបចំ និង ការប្រព្រឹត្តទៅ នៃក្រសួងសេដ្ឋកិច្ច និង ហិរញ្ញវត្ថុ
- បានឃើញព្រះរាជក្រមលេខ ០១/នស/៩៣ ,ចុះថ្ងៃទី ២៨ ខែ ធ្នូ ឆ្នាំ ១៩៩៣ ដែលប្រកាសអោយប្រើច្បាប់ស្តីអំពីប្រព័ន្ធហិរញ្ញវត្ថុ ដែលត្រូវបានកែប្រែដោយច្បាប់ស្តីពីហិរញ្ញវត្ថុ សំរាប់ការគ្រប់គ្រងឆ្នាំ ១៩៩៥ ដែលប្រកាសអោយប្រើដោយព្រះរាជក្រម លេខ ១១/នស/៩៤ , ចុះថ្ងៃទី ៣១ ខែ ធ្នូ ឆ្នាំ ១៩៩៤ និង ត្រូវបានកែប្រែដោយច្បាប់ស្តីពីហិរញ្ញវត្ថុសំរាប់ការគ្រប់គ្រង ឆ្នាំ ២០០០ ដែលប្រកាសអោយប្រើដោយព្រះរាជក្រមលេខ នស/រកម/១២៩៩/១៥ , ចុះថ្ងៃទី ២៥ ខែ ធ្នូ ឆ្នាំ ១៩៩៩
- បានឃើញព្រះរាជក្រមលេខ នស/រកម/១២០១/១៥ , ចុះថ្ងៃទី ៣១ ខែ ធ្នូ ឆ្នាំ ២០០១ ដែលប្រកាសអោយប្រើច្បាប់ស្តីពីហិរញ្ញវត្ថុ សំរាប់ការគ្រប់គ្រង ឆ្នាំ ២០០២
- បានឃើញអនុក្រឹត្យ លេខ ០៣ អនក្រ.បក , ចុះថ្ងៃទី ០៤ ខែ មករា ឆ្នាំ ២០០២ ស្តីពីការបែងចែកឥណទានថវិកាចំណាយ តាមជំពូក នៃច្បាប់ស្តីពីហិរញ្ញវត្ថុ សំរាប់ការគ្រប់គ្រងឆ្នាំ ២០០២
- បានឃើញអនុក្រឹត្យ លេខ ០៤ អនក្រ.បក , ចុះថ្ងៃទី ០៤ ខែ មករា ឆ្នាំ ២០០២ ស្តីពីការផ្ទេរឥណទានថវិកា
- តាមសំណើរបស់រដ្ឋមន្ត្រីក្រសួងសេដ្ឋកិច្ច និង ហិរញ្ញវត្ថុ

## សម្រេច

**មាត្រា១:** ត្រូវបានអនុញ្ញាតអោយផ្ទេរឥណទានថវិកា ចំនួន ១.០០០ លានរៀល ( មួយពាន់លានរៀល ) ពីជំពូក ៤១ (ចំណាយមិនបានគ្រោងទុក ) នៃខ្ទង់ចំណាយមិនទាន់បែងចែក មកជំពូក ១១ ( ចំណាយដំណើរការរដ្ឋបាល សំភារៈ និងការជួសជុលតូច ) របស់ក្រសួងសេដ្ឋកិច្ច និង ហិរញ្ញវត្ថុ សំរាប់ការគ្រប់គ្រងឆ្នាំ ២០០២ ។

**មាត្រា២:** ការបែងចែកឥណទានថវិកាចំណាយផ្ទៃក្នុងជំពូកទាំងនេះ តាមប្រការ កថាខ័ណ្ឌ និង វាក្យខ័ណ្ឌ ត្រូវធ្វើឡើង ដោយប្រកាសរដ្ឋមន្ត្រីក្រសួងសេដ្ឋកិច្ច និង ហិរញ្ញវត្ថុ សំរាប់ទូទាត់ថ្លៃសេវាទូរស័ព្ទអចល័តអាយឌីឌី ។

**មាត្រា៣:** រដ្ឋមន្ត្រីទទួលបន្ទុកទីស្តីការគណៈរដ្ឋមន្ត្រី រដ្ឋមន្ត្រីក្រសួងសេដ្ឋកិច្ច និង ហិរញ្ញវត្ថុ ត្រូវទទួលបន្ទុកអនុវត្តអនុក្រឹត្យនេះ ចាប់ពីថ្ងៃចុះហត្ថលេខាតទៅ ។

រាជធានីភ្នំពេញ , ថ្ងៃទី ០១ ខែ កក្កដា ឆ្នាំ ២០០២

នាយករដ្ឋមន្ត្រី

ហ៊ុន សែន

**កន្លែងទទួល**

- ក្រសួងព្រះបរមរាជវាំង
- អគ្គលេខាធិការដ្ឋានព្រឹទ្ធសភា
- អគ្គលេខាធិការដ្ឋានរដ្ឋសភា
- ខុទ្ទកាល័យសម្តេចនាយករដ្ឋមន្ត្រី
- ដូចមាត្រា ៣
- កាលប្បវត្តិ - ឯកសារ

បានយកសេចក្តីជំរាបជូន
សម្តេចនាយករដ្ឋមន្ត្រី ដើម្បីចុះហត្ថលេខា

គាត ឈន់

ទេសរដ្ឋមន្ត្រី
រដ្ឋមន្ត្រីក្រសួងសេដ្ឋកិច្ច និង ហិរញ្ញវត្ថុ

**ព្រះរាជាណាចក្រកម្ពុជា**

**ជាតិ សាសនា ព្រះមហាក្សត្រ**

រាជរដ្ឋាភិបាលកម្ពុជា

លេខ : ៤៥ អនក្រ.បក

# អនុក្រឹត្យ

## ស្តីពីការផ្ទេរឥណទានថវិកា

### រាជរដ្ឋាភិបាល

- បានឃើញរដ្ឋធម្មនុញ្ញនៃព្រះរាជាណាចក្រកម្ពុជា
- បានឃើញព្រះរាជក្រឹត្យលេខ នស/រកត/១១៩៨/៧២ , ចុះថ្ងៃទី ៣០ ខែ វិច្ឆិកា ឆ្នាំ ១៩៩៨ ស្តីពីការតែងតាំងរាជរដ្ឋាភិបាលនៃព្រះរាជាណាចក្រកម្ពុជា
- បានឃើញព្រះរាជក្រមលេខ ០២/នស/៩៤ , ចុះថ្ងៃទី ២០ ខែ កក្កដា ឆ្នាំ ១៩៩៤ ដែលប្រកាសអោយប្រើច្បាប់ស្តីពីការរៀបចំ និង ការប្រព្រឹត្តទៅនៃគណៈរដ្ឋមន្ត្រី
- បានឃើញព្រះរាជក្រមលេខ នស/រកម/០១៩៦/១៨ , ចុះថ្ងៃទី ២៤ ខែ មករា ឆ្នាំ ១៩៩៦ ដែលប្រកាសអោយប្រើច្បាប់ស្តីពីការបង្កើតក្រសួងសេដ្ឋកិច្ច និង ហិរញ្ញវត្ថុ
- បានឃើញអនុក្រឹត្យលេខ ០៤ អនក្រ.បក , ចុះថ្ងៃទី ២០ ខែ មករា ឆ្នាំ ២០០០ ស្តីពីការរៀបចំ និង ការប្រព្រឹត្តទៅ នៃក្រសួងសេដ្ឋកិច្ច និង ហិរញ្ញវត្ថុ
- បានឃើញព្រះរាជក្រមលេខ ០១/នស/៩៣ ,ចុះថ្ងៃទី ២៨ ខែ ធ្នូ ឆ្នាំ ១៩៩៣ ដែលប្រកាសអោយប្រើច្បាប់ស្តីអំពីប្រព័ន្ធហិរញ្ញវត្ថុ ដែលត្រូវបានកែប្រែដោយច្បាប់ស្តីពីហិរញ្ញវត្ថុ សំរាប់ការគ្រប់គ្រងឆ្នាំ ១៩៩៥ ដែលប្រកាសអោយប្រើដោយព្រះរាជក្រមលេខ ១១/នស/៩៤ , ចុះថ្ងៃទី ៣១ ខែ ធ្នូ ឆ្នាំ ១៩៩៤ និង ត្រូវបានកែប្រែដោយច្បាប់ស្តីពីហិរញ្ញវត្ថុសំរាប់ការគ្រប់គ្រង ឆ្នាំ ២០០០ ដែលប្រកាសអោយប្រើដោយព្រះរាជក្រមលេខ នស/រកម/១២៩៩/១៥ , ចុះថ្ងៃទី ២៥ ខែ ធ្នូ ឆ្នាំ ១៩៩៩
- បានឃើញព្រះរាជក្រមលេខ នស/រកម/១២០១/១៥ , ចុះថ្ងៃទី ៣១ ខែ ធ្នូ ឆ្នាំ ២០០១ ដែលប្រកាសអោយប្រើច្បាប់ស្តីពីហិរញ្ញវត្ថុ សំរាប់ការគ្រប់គ្រង ឆ្នាំ ២០០២
- បានឃើញអនុក្រឹត្យលេខ ០៣ អនក្រ.បក , ចុះថ្ងៃទី ០៤ ខែ មករា ឆ្នាំ ២០០២ ស្តីពីការបែងចែកឥណទានថវិកាចំណាយតាមជំពូក នៃច្បាប់ស្តីពីហិរញ្ញវត្ថុ សំរាប់ការគ្រប់គ្រងឆ្នាំ ២០០២
- បានឃើញអនុក្រឹត្យលេខ ០៤ អនក្រ.បក,ចុះថ្ងៃទី ០៤ ខែ មករា ឆ្នាំ ២០០២ ស្តីពីការផ្ទេរឥណទានថវិកា
- តាមសំណើរបស់ក្រសួងសេដ្ឋកិច្ច និង ហិរញ្ញវត្ថុ

## សំរេច

**មាត្រា១:** ត្រូវបានអនុញ្ញាតអោយផ្ទេរឥណទានថវិកា ចំនួន ៥,០០០ លានរៀល ( ប្រាំពាន់លានរៀលគត់ ) ពីជំពូក ៤០ ( ចំណាយផ្សេងៗ ) នៃខ្ទង់ចំណាយមិនទាន់បែងចែក មកជំពូក ១១ ( ចំណាយដំណើរការរដ្ឋបាល សំភារៈ និង ការផ្គត់ផ្គង់តូច ) របស់ទីស្តីការគណៈរដ្ឋមន្ត្រី សំរាប់ការគ្រប់គ្រង ឆ្នាំ ២០០២ ។

**មាត្រា២:** ការបែងចែកឥណទានថវិកាចំណាយផ្ទៃក្នុងជំពូកទាំងនេះ តាមប្រការ កថាខ័ណ្ឌ និង វាក្យខ័ណ្ឌ ត្រូវធ្វើឡើងដោយប្រកាសរបស់រដ្ឋមន្ត្រីក្រសួងសេដ្ឋកិច្ច និង ហិរញ្ញវត្ថុ សំរាប់ចំណាយដំណើរការរដ្ឋបាល ដែលខ្វះក្នុងឆ្នាំ ២០០២ ។

**មាត្រា៣:** រដ្ឋមន្ត្រីទទួលបន្ទុកទីស្តីការគណៈរដ្ឋមន្ត្រី រដ្ឋមន្ត្រីក្រសួងសេដ្ឋកិច្ច និង ហិរញ្ញវត្ថុ ត្រូវទទួលបន្ទុកអនុវត្តអនុក្រឹត្យនេះ ចាប់ពីថ្ងៃចុះហត្ថលេខាតទៅ ។

រាជធានីភ្នំពេញ, ថ្ងៃទី ០៤ ខែកក្កដា ឆ្នាំ ២០០២

នាយករដ្ឋមន្ត្រី

ហ៊ុន សែន

**កន្លែងទទួល**

- ក្រសួងព្រះបរមរាជវាំង
- អគ្គលេខាធិការដ្ឋានព្រឹទ្ធសភា
- អគ្គលេខាធិការដ្ឋានរដ្ឋសភា
- ខុទ្ទកាល័យសម្តេចនាយករដ្ឋមន្ត្រី
- ដូចមាត្រា ៣
- កាលប្បវត្តិ - ឯកសារ

បានយកសេចក្តីជំរាបជូន
សម្តេចនាយករដ្ឋមន្ត្រី ដើម្បីចុះហត្ថលេខា

គាត ឈន់

ទេសរដ្ឋមន្ត្រី
រដ្ឋមន្ត្រីក្រសួងសេដ្ឋកិច្ច និង ហិរញ្ញវត្ថុ

**ព្រះរាជាណាចក្រកម្ពុជា**

**ជាតិ សាសនា ព្រះមហាក្សត្រ**

រាជរដ្ឋាភិបាលកម្ពុជា

លេខ :...៧១៩...អនក្រ.បក

# អនុក្រឹត្យ

## ស្តីពី

## ការតែងតាំងក្រុមប្រឹក្សាភិបាល សំរាប់ដឹកនាំវិទ្យាស្ថានស្រាវជ្រាវកៅស៊ូកម្ពុជា

### រាជរដ្ឋាភិបាល

- បានឃើញរដ្ឋធម្មនុញ្ញ នៃព្រះរាជាណាចក្រកម្ពុជា
- បានឃើញព្រះរាជក្រឹត្យលេខ នស/រកត/១១៩៨/៧២ ចុះថ្ងៃទី ៣០ ខែ វិច្ឆិកា ឆ្នាំ ១៩៩៨ ស្តីពីការតែងតាំងរាជរដ្ឋាភិបាល នៃព្រះរាជាណាចក្រកម្ពុជា
- បានឃើញព្រះរាជក្រមលេខ ០២/នស/៩៤ ចុះថ្ងៃទី ២០ ខែ កក្កដា ឆ្នាំ ១៩៩៤ ដែលប្រកាសអោយប្រើច្បាប់ស្តីពីការរៀបចំ និង ការប្រព្រឹត្តទៅនៃគណៈរដ្ឋមន្ត្រី
- បានឃើញព្រះរាជក្រមលេខ នស/រកម/០១៩៦/១៣ ចុះថ្ងៃទី ២៤ ខែ មករា ឆ្នាំ ១៩៩៦ ដែលប្រកាសអោយប្រើច្បាប់ ស្តីពីការបង្កើតក្រសួងកសិកម្ម រុក្ខាប្រមាញ់ និង នេសាទ
- បានឃើញអនុក្រឹត្យលេខ ៦៥ អនក្រ.បក ចុះថ្ងៃទី ១៧ ខែ តុលា ឆ្នាំ ១៩៩៧ ស្តីពីការបង្កើតវិទ្យាស្ថានស្រាវជ្រាវកៅស៊ូកម្ពុជា
- យោងតាមសំណើរបស់ក្រសួងកសិកម្ម រុក្ខាប្រមាញ់ និង នេសាទ

### សំរេច

**មាត្រា ១ :** ត្រូវបានតែងតាំងក្រុមប្រឹក្សាភិបាល សំរាប់ដឹកនាំវិទ្យាស្ថានស្រាវជ្រាវកៅស៊ូកម្ពុជា ដែលមានសមាសភាពដូចខាងក្រោម ៖

| | | | |
|---|---|---|---|
| ១_ឯកឧត្តម | គុំ សារ៉ុន | តំណាងក្រសួងកសិកម្ម រុក្ខាប្រមាញ់ និង នេសាទ | ជាប្រធាន |
| ២_ឯកឧត្តម | លី ផល្លា | ប្រធានអគ្គនាយកដ្ឋានចំការកៅស៊ូ | ជាសមាជិកស្វ័យប្រវត្តិ |
| ៣_ឯកឧត្តម | ម៉ក់ គីមហុង | តំណាងអ្នកដាំកៅស៊ូ | ជាសមាជិក |
| ៤_លោក | ម៉ម ប៊ុន | តំណាងក្រសួងសេដ្ឋកិច្ច និង ហិរញ្ញវត្ថុ | ជាសមាជិក |
| ៥_លោក | យិន សុង | នាយកវិទ្យាស្ថានស្រាវជ្រាវកៅស៊ូកម្ពុជា | ជាសមាជិកស្វ័យប្រវត្តិ |
| ៦_លោក | សៀក ពិសិដ្ឋ | តំណាងអ្នកដាំកៅស៊ូ | ជាសមាជិក |
| ៧_លោក | ហ៊ុន គីមសាន | តំណាងបុគ្គលិកវិទ្យាស្ថាន | ជាសមាជិកស្វ័យប្រវត្តិ |

**មាត្រា ២ :** រដ្ឋមន្ត្រីទទួលបន្ទុកទីស្តីការគណៈរដ្ឋមន្ត្រី រដ្ឋមន្ត្រីក្រសួងកសិកម្ម រុក្ខាប្រមាញ់ និង នេសាទ រដ្ឋមន្ត្រីក្រសួងសេដ្ឋកិច្ច និង ហិរញ្ញវត្ថុ វិទ្យាស្ថានស្រាវជ្រាវកៅស៊ូកម្ពុជា រដ្ឋលេខាធិការនៃរដ្ឋលេខាធិការដ្ឋានមុខងារសាធារណៈ សហរដ្ឋមន្ត្រី រដ្ឋមន្ត្រី រដ្ឋលេខាធិការ គ្រប់ក្រសួងស្ថាប័នពាក់ព័ន្ធ និង សាមីខ្លួន ត្រូវអនុវត្តអនុក្រឹត្យនេះ ចាប់ពីថ្ងៃចុះហត្ថលេខាតទៅ ៕

*រាជធានីភ្នំពេញ ថ្ងៃទី ០១ ខែ កក្កដា ឆ្នាំ ២០០២*

**នាយករដ្ឋមន្ត្រី**

**ហ៊ុន សែន**

**កន្លែងទទួល**

- *ក្រសួងព្រះបរមរាជវាំង*
- *អគ្គលេខាធិការដ្ឋានព្រឹទ្ធសភា*
- *អគ្គលេខាធិការដ្ឋានរដ្ឋសភា*
- *ខុទ្ទកាល័យសម្តេចនាយករដ្ឋមន្ត្រី*
- *ដូចមាត្រា ២*
- *ឯកសារ_កាលប្បវត្តិ*

# ព្រះរាជាណាចក្រកម្ពុជា

## ជាតិ សាសនា ព្រះមហាក្សត្រ

**រាជរដ្ឋាភិបាលកម្ពុជា**

លេខ:.....៧៤០...អនក្រ.តត

## អនុក្រឹត្យ

## ស្តីពីការជូនមេដាយការងារ

* * * * *

## រាជរដ្ឋាភិបាល

- បានឃើញរដ្ឋធម្មនុញ្ញ នៃព្រះរាជាណាចក្រកម្ពុជា
- បានឃើញព្រះរាជក្រឹត្យលេខ នស/រកត/១១៩៨/៧២ ចុះថ្ងៃទី ៣០ ខែ វិច្ឆិកា ឆ្នាំ ១៩៩៨ ស្តីពីការតែងតាំងរាជរដ្ឋាភិបាល នៃព្រះរាជាណាចក្រកម្ពុជា
- បានឃើញព្រះរាជក្រមលេខ ០២/នស/៩៤ ចុះថ្ងៃទី ២០ ខែ កក្កដា ឆ្នាំ ១៩៩៤ ដែលប្រកាសអោយប្រើច្បាប់ ស្តីពីការរៀបចំ និងការប្រព្រឹត្តទៅ នៃគណៈរដ្ឋមន្ត្រី
- បានឃើញព្រះរាជក្រឹត្យលេខ ជស/រកត/១០៩៥/០១ ចុះថ្ងៃទី ០៥ ខែ តុលា ឆ្នាំ ១៩៩៥ ស្តីពីការបង្កើត និង ប្រើប្រាស់គ្រឿងឥស្សរិយយស នៃព្រះរាជាណាចក្រកម្ពុជា
- តាមសំណើរបស់គណៈកម្មការពិនិត្យលក្ខណសម្បត្តិវរជនដែលត្រូវជូនគ្រឿងឥស្សរិយយស

## ស ម្រេ ច

**មាត្រា ១ :** ត្រូវបានបំពាក់ **មេដាយការងារ** តាមលំដាប់ថ្នាក់ ជូនមន្ត្រី ០៣ រូប ដែលមានស្នាដៃក្នុងការទំនាក់ទំនងស្វែងរក ជំនួយពីបរទេស សំរាប់ជួយដល់ប្រជាពលរដ្ឋកម្ពុជា មានតំលៃចំនួន ២១.២៤០ USD ដូចមានរាយនាមខាងក្រោម ÷

**ក-មេដាយមាសការងារ :**

១-ឯកឧត្តមបណ្ឌិត **គៅ** **ម៉ុនហុង** អគ្គមេធាវីរាជរដ្ឋាភិបាល

២-លោកវេជ្ជបណ្ឌិត **ហេង** **សុខ** ប្រធានអង្គការសាក់ស៊ីវ ( SACIWHR)

**ខ-មេដាយប្រាក់ការងារ :**

-លោក **យូ** **សុជាវិទ្ធ** អគ្គហិរញ្ញិកអង្គការសាក់ស៊ីវ ( SACIWHR )

**មាត្រា ២ :** រដ្ឋមន្ត្រីទទួលបន្ទុកទីស្តីការគណៈរដ្ឋមន្ត្រី និង គណៈកម្មការពិនិត្យលក្ខណសម្បត្តិវរជន ដែលត្រូវជូនគ្រឿងឥស្សរិយយស ត្រូវអនុវត្តអនុក្រឹត្យនេះ អោយទទួលបានលទ្ធផលល្អ ។

រាជធានីភ្នំពេញ ថ្ងៃទី ០៧ ខែ កក្កដា ឆ្នាំ ២០០២

**នាយករដ្ឋមន្ត្រី**

**ហ៊ុន សែន**

**កន្លែងទទួល :**

- ក្រសួងព្រះបរមរាជវាំង
- អគ្គលេខាធិការដ្ឋានព្រឹទ្ធសភា
- អគ្គលេខាធិការដ្ឋានរដ្ឋសភា
- ខុទ្ទកាល័យសម្តេចនាយករដ្ឋមន្ត្រី
- ដូចក្នុងមាត្រា ១ និង មាត្រា ២
- រាជកិច្ច
- ឯកសារ- កាលប្បវត្តិ

**ព្រះរាជាណាចក្រកម្ពុជា**

**ជាតិ សាសនា ព្រះមហាក្សត្រ**

**រាជរដ្ឋាភិបាលកម្ពុជា**

លេខៈ ៣៧១ អនក្រ.បក

# អនុក្រឹត្យ

## ស្តីពីការតែងតាំងមន្ត្រីរាជការ

*******

## រាជរដ្ឋាភិបាល

- បានឃើញរដ្ឋធម្មនុញ្ញនៃព្រះរាជាណាចក្រកម្ពុជា
- បានឃើញព្រះរាជក្រឹត្យលេខ នស/រកត/១១៩៨/៧២ ចុះថ្ងៃទី ៣០ ខែវិច្ឆិកា ឆ្នាំ១៩៩៨ ស្តីពីការតែងតាំងរាជរដ្ឋាភិបាលនៃព្រះរាជាណាចក្រកម្ពុជា
- បានឃើញព្រះរាជក្រមលេខ ០២/នស/៩៤ ចុះថ្ងៃទី ២០ ខែកក្កដា ឆ្នាំ១៩៩៤ ដែលប្រកាសឱ្យប្រើច្បាប់ ស្តីពីការរៀបចំ និងការប្រព្រឹត្តទៅនៃគណៈរដ្ឋមន្ត្រី
- បានឃើញអនុក្រឹត្យលេខ ២១ អនក្រ.បក ចុះថ្ងៃទី ២៣ ខែមីនា ឆ្នាំ១៩៩៨ ស្តីពីការរៀបចំ និងការប្រព្រឹត្តទៅរបស់ក្រសួងអប់រំ យុវជន និងកីឡា
- យោងតាមសំណើរបស់រដ្ឋមន្ត្រីក្រសួងអប់រំ យុវជន និងកីឡា

## ស ំ រេ ច

**មាត្រា ១** : ត្រូវបានតែងតាំងមន្ត្រីថ្នាក់ព្រឹទ្ធបុរសមហាវិទ្យាល័យ ចំនួន ០២រូបរបស់ក្រសួងអប់រំ យុវជន និងកីឡា ដូចមានរាយនាមខាងក្រោម ៖

១- លោក **ហង់ ចាន់ថុន** ជាព្រឹទ្ធបុរសមហាវិទ្យាល័យវិទ្យាសាស្ត្រ

២- លោក **ម៉ុញ្ញ សារី** ជាព្រឹទ្ធបុរសមហាវិទ្យាល័យអក្សរសាស្ត្រ - មនុស្សសាស្ត្រ

**មាត្រា ២** : រដ្ឋមន្ត្រីទទួលបន្ទុកទីស្តីការគណៈរដ្ឋមន្ត្រី រដ្ឋមន្ត្រីក្រសួងសេដ្ឋកិច្ច និងហិរញ្ញវត្ថុ រដ្ឋមន្ត្រីក្រសួងអប់រំ យុវជន និងកីឡា រដ្ឋលេខាធិការនៃរដ្ឋលេខាធិការដ្ឋានមុខងារសាធារណៈ

រដ្ឋមន្ត្រី រដ្ឋលេខាធិការគ្រប់ក្រសួង ស្ថាប័នពាក់ព័ន្ធ និងសាមីខ្លួនត្រូវអនុវត្តអនុក្រឹត្យនេះ ចាប់ពីថ្ងៃចុះហត្ថលេខាតទៅ ។

រាជធានីភ្នំពេញ , ថ្ងៃទី ០២ ខែ កក្កដា ឆ្នាំ ២០០២

នាយករដ្ឋមន្ត្រី

ហ៊ុន សែន

**កន្លែងទទួល**

- ក្រសួងព្រះបរមរាជវាំង
- អគ្គលេខាធិការដ្ឋានព្រឹទ្ធសភា
- អគ្គលេខាធិការដ្ឋានរដ្ឋសភា
- ខុទ្ទកាល័យសម្តេចនាយករដ្ឋមន្ត្រី
- ដូចមាត្រា ២
- ឯកសារ - កាលប្បវត្តិ

41

# ព្រះរាជាណាចក្រកម្ពុជា

**រាជរដ្ឋាភិបាលកម្ពុជា** **ជាតិ សាសនា ព្រះមហាក្សត្រ**

លេខ:...៨៧.២...អនក្រ.បក

## អនុក្រឹត្យ

## ស្តីពីការតែងតាំងបេសកជន

*******

## រាជរដ្ឋាភិបាល

-បានឃើញរដ្ឋធម្មនុញ្ញនៃព្រះរាជាណាចក្រកម្ពុជា

-បានឃើញព្រះរាជក្រឹត្យលេខ នស/រកត/១១៩៨/៧២ ចុះថ្ងៃទី ៣០ ខែវិច្ឆិកា ឆ្នាំ១៩៩៨ ស្តីពីការតែងតាំងរាជរដ្ឋាភិបាលនៃព្រះរាជាណាចក្រកម្ពុជា

-បានឃើញព្រះរាជក្រមលេខ ០២/នស/៩៤ ចុះថ្ងៃទី ២០ ខែកក្កដា ឆ្នាំ១៩៩៤ ដែលប្រកាសអោយប្រើច្បាប់ ស្តីពីការរៀបចំ និងការប្រព្រឹត្តទៅនៃគណៈរដ្ឋមន្ត្រី

-បានឃើញអនុក្រឹត្យលេខ ៦២ អនក្រ.បក ចុះថ្ងៃទី ១៤ ខែតុលា ឆ្នាំ ១៩៩៧ ស្តីពីការរៀបចំ និងការប្រព្រឹត្តទៅរបស់ក្រសួងវប្បធម៌និងវិចិត្រសិល្បៈ

-យោងតាមសំណើរបស់រដ្ឋមន្ត្រីក្រសួងវប្បធម៌ និងវិចិត្រសិល្បៈ

## សំរេច

**មាត្រា ១** : ត្រូវបានតែងតាំងលោកស្រី **ឡោះណាំ ស៊ីផារ** ជាបេសកជនរបស់សម្តេចព្រះរាមរដ្ឋមន្ត្រីក្រសួងវប្បធម៌ និងវិចិត្រសិល្បៈ ។

**មាត្រា ២** : រដ្ឋមន្ត្រីទទួលបន្ទុកទីស្តីការគណៈរដ្ឋមន្ត្រី រដ្ឋមន្ត្រីក្រសួងសេដ្ឋកិច្ច និងហិរញ្ញវត្ថុ រដ្ឋមន្ត្រីក្រសួងវប្បធម៌និងវិចិត្រសិល្បៈ រដ្ឋលេខាធិការនៃរដ្ឋលេខាធិការដ្ឋានមុខងារសាធារណៈ រដ្ឋមន្ត្រី រដ្ឋលេខាធិការគ្រប់ក្រសួង ស្ថាប័នពាក់ព័ន្ធ និងសាមីខ្លួនត្រូវអនុវត្តអនុក្រឹត្យនេះ ចាប់ពីថ្ងៃចុះហត្ថលេខានេះតទៅ ។

រាជធានីភ្នំពេញ ថ្ងៃទី ១៧ ខែកក្កដា ឆ្នាំ ២០០២

នាយករដ្ឋមន្ត្រី

ហ៊ុន សែន

**កន្លែងទទួល** :

- ក្រសួងព្រះបរមរាជវាំង
- អគ្គលេខាធិការដ្ឋានព្រឹទ្ធសភា
- អគ្គលេខាធិការដ្ឋានរដ្ឋសភា
- ខុទ្ទកាល័យសម្តេចនាយករដ្ឋមន្ត្រី
- ដូចមាត្រា ២
- ឯកសារ - កាលប្បវត្តិ

**ព្រះរាជាណាចក្រកម្ពុជា**

ជាតិ សាសនា ព្រះមហាក្សត្រ

រាជរដ្ឋាភិបាលកម្ពុជា

លេខ : ៣២៣ អនក្រ.បក

# អនុក្រឹត្យ
## ស្តីពី
## ការតម្លើងឋានន្តរសក្តិនាយនគរបាលជាតិ

## រាជរដ្ឋាភិបាល

- បានឃើញរដ្ឋធម្មនុញ្ញ នៃព្រះរាជាណាចក្រកម្ពុជា
- បានឃើញព្រះរាជក្រឹត្យលេខនស/រកត / ១១៩៨ / ៧២ ចុះថ្ងៃទី ៣០ ខែ វិច្ឆកា ឆ្នាំ ១៩៩៨ ស្តីពីការតែងតាំងរាជរដ្ឋាភិបាល នៃព្រះរាជាណាចក្រកម្ពុជា
- បានឃើញព្រះរាជក្រមលេខ ០២ នស/៩៤ ចុះថ្ងៃទី ២០ ខែ កក្កដា ឆ្នាំ ១៩៩៤ ដែលប្រកាសអោយ ប្រើច្បាប់ ស្តីពីការរៀបចំ និង ការប្រព្រឹត្តិទៅនៃគណៈរដ្ឋមន្ត្រី
- បានឃើញព្រះរាជក្រមលេខនស / រកម / ០១៩៦ / ០៨ ចុះថ្ងៃទី ២៤ ខែ មករា ឆ្នាំ ១៩៩៦ ដែលប្រកាសអោយប្រើច្បាប់ ស្តីពីការបង្កើតក្រសួងមហាផ្ទៃ
- យោងតាមសំណើរបស់សហរដ្ឋមន្ត្រីក្រសួងមហាផ្ទៃ

## សំរេច

**មាត្រា១ :** ត្រូវបានតម្លើងឋានន្តរសក្តិថ្នាក់ **វរៈសេនីយ៍ឯក** ជូនលោកវរៈសេនីយ៍ទោ **ជោត សំរាំង** អត្តលេខ ០៦៧៤ អនុប្រធានលេខាធិការដ្ឋាន ក្រុមអ្នកច្បាប់ នៃ ក្រសួងមហាផ្ទៃ ។

**មាត្រា២ :** រដ្ឋមន្ត្រីទទួលបន្ទុកទីស្តីការគណៈរដ្ឋមន្ត្រី សហរដ្ឋមន្ត្រីក្រសួងមហាផ្ទៃ រដ្ឋមន្ត្រីក្រសួងសេដ្ឋកិច្ច និង ហិរញ្ញវត្ថុ រដ្ឋលេខាធិការ នៃរដ្ឋលេខាធិការដ្ឋានមុខងារសាធារណៈ សហរដ្ឋមន្ត្រី រដ្ឋមន្ត្រី រដ្ឋលេខាធិការគ្រប់ក្រសួង ស្ថាប័នដែលពាក់ព័ន្ធ និង សាមីខ្លួនត្រូវអនុវត្តតាមអនុក្រឹត្យនេះចាប់ពីថ្ងៃចុះហត្ថលេខាតទៅ ។

*រាជធានីភ្នំពេញ. ថ្ងៃទី ០៤ ខែ កក្កដា ឆ្នាំ ២០០២*

**ហ៊ុន សែន**

*កន្លែងទទួល*
- *ក្រសួងព្រះបរមរាជវាំង*
- *អគ្គលេខាធិការដ្ឋានព្រឹទ្ធសភា*
- *អគ្គលេខាធិការដ្ឋានរដ្ឋសភា*
- *ខុទ្ទកាល័យសម្តេចនាយករដ្ឋមន្ត្រី*
- *ខុទ្ទកាល័យឧបនាយករដ្ឋមន្ត្រី*
- *ដូចមាត្រា ២*
- *ឯកសារ-កាលប្បវត្តិ*

**ព្រះរាជាណាចក្រកម្ពុជា**
ជាតិ សាសនា ព្រះមហាក្សត្រ

រាជរដ្ឋាភិបាលកម្ពុជា
លេខ : ៣២៤ អនក្រ.តត

# អនុក្រឹត្យ

## ស្តីពីការតម្លើងឋានន្តរសក្តិនាយនគរបាលជាតិ ជាកិច្ចបច្ឆាមរណៈ

## រាជរដ្ឋាភិបាល

-បានឃើញរដ្ឋធម្មនុញ្ញ នៃព្រះរាជាណាចក្រកម្ពុជា

-បានឃើញព្រះរាជក្រឹត្យលេខ នស / រកត / ១១៩៨ / ៧២ ចុះថ្ងៃទី ៣០ ខែ វិច្ឆិកា ឆ្នាំ១៩៩៨ ស្តីពីការតែងតាំង រាជរដ្ឋាភិបាល នៃព្រះរាជាណាចក្រកម្ពុជា

-បានឃើញព្រះរាជក្រមលេខ នស/៩៤/ ០២ ចុះថ្ងៃទី ២០ ខែ កក្កដា ឆ្នាំ១៩៩៤ ដែលប្រកាសអោយប្រើច្បាប់ស្តីពីការរៀបចំ និង ការប្រព្រឹត្តិទៅនៃគណៈរដ្ឋមន្ត្រី

-បានឃើញព្រះរាជក្រមលេខ នស / រកម / ០១៩៦ / ០៨ ចុះថ្ងៃទី ២៤ ខែ មករា ឆ្នាំ ១៩៩៦ ដែលប្រកាសអោយប្រើច្បាប់ស្តីពីការបង្កើតក្រសួងមហាផ្ទៃ

-បានឃើញព្រះរាជក្រឹត្យលេខ នស/ រកត / ០៥០១ / ១៧៨ ចុះថ្ងៃទី ២២ ខែ ឧសភា ឆ្នាំ ២០០១ ស្តីពីលក្ខន្តិកៈដោយឡែក នៃក្របខ័ណ្ឌមន្ត្រីនគរបាលជាតិកម្ពុជា នៃក្រសួងមហាផ្ទៃ ។

-យោងតាមសំណើរបស់សហរដ្ឋមន្ត្រីក្រសួងមហាផ្ទៃ

## សំរេច

**មាត្រា ១ :** ត្រូវបានតម្លើងឋានន្តរសក្តិថ្នាក់ **វរៈសេនីយ៍ឯក** ជាកិច្ចបច្ឆាមរណៈ ជូនចំពោះសពលោកវរៈសេនីយ៍ទោ **ចាន់ សង្គ្រាម** ស្នងការរង នៃស្នងការដ្ឋាននគរបាលខេត្តកោះកុង ។

**មាត្រា ២ :** រដ្ឋមន្ត្រីទទួលបន្ទុកទីស្តីការគណៈរដ្ឋមន្ត្រី សហរដ្ឋមន្ត្រីក្រសួងមហាផ្ទៃ រដ្ឋមន្ត្រីក្រសួងសេដ្ឋកិច្ច និងហិរញ្ញវត្ថុ រដ្ឋលេខាធិការ នៃរដ្ឋលេខាធិការដ្ឋានមុខងារសាធារណៈ សហរដ្ឋមន្ត្រី រដ្ឋមន្ត្រី រដ្ឋលេខាធិការ គ្រប់ក្រសួងស្ថាប័នដែលពាក់ព័ន្ធ ត្រូវអនុវត្តអនុក្រឹត្យនេះចាប់ពីថ្ងៃចុះហត្ថលេខាតទៅ ។

រាជធានីភ្នំពេញ, ថ្ងៃទី ០៤ ខែ កក្កដា ឆ្នាំ ២០០២

នាយករដ្ឋមន្ត្រី

ហ៊ុន សែន

*ចម្លងជូន :*
- *ក្រសួងព្រះបរមរាជវាំង*
- *អគ្គលេខាធិការដ្ឋានព្រឹទ្ធសភា*
- *អគ្គលេខាធិការដ្ឋានរដ្ឋសភា*
- *ខុទ្ទកាល័យសម្តេចនាយករដ្ឋមន្ត្រី*
- *ខុទ្ទកាល័យឧបនាយករដ្ឋមន្ត្រី*
- *ដូចមាត្រា ២*
- *ឯកសារ-កាលប្បវត្តិ*

**ព្រះរាជាណាចក្រកម្ពុជា**
**ជាតិ សាសនា ព្រះមហាក្សត្រ**

រាជរដ្ឋាភិបាលកម្ពុជា
លេខៈ ៣៤៥ អនក្រ.តត

# អនុក្រឹត្យ

## ស្តីពី

## ការតែងតាំងសមាជិកក្រុមប្រឹក្សាភិបាល អាណត្តិទី ២ នៃរដ្ឋាករទឹកស្វយ័តក្រុងភ្នំពេញ

## រាជរដ្ឋាភិបាល

- បានឃើញរដ្ឋធម្មនុញ្ញ នៃព្រះរាជាណាចក្រកម្ពុជា
- បានឃើញព្រះរាជក្រឹត្យលេខ នស/រកត/១១៩៨/៧២ ចុះថ្ងៃទី ៣០ ខែ វិច្ឆិកា ឆ្នាំ ១៩៩៨ ស្តីពីការតែងតាំងរាជរដ្ឋាភិបាល នៃព្រះរាជាណាចក្រកម្ពុជា
- បានឃើញព្រះរាជក្រមលេខ ០២/នស/៩៤ ចុះថ្ងៃទី ២០ ខែ កក្កដា ឆ្នាំ ១៩៩៤ ដែលប្រកាសអោយប្រើច្បាប់ស្តីពីការរៀបចំ និង ការប្រព្រឹត្តទៅនៃគណៈរដ្ឋមន្ត្រី
- បានឃើញអនុក្រឹត្យលេខ ៥២ អនក្រ.បក ចុះថ្ងៃទី ១៩ ខែ ធ្នូ ឆ្នាំ ១៩៩៦ ស្តីពីការបង្កើតរដ្ឋាករទឹកស្វយ័តក្រុងភ្នំពេញ
- បានឃើញអនុក្រឹត្យលេខ ៣៤ អនក្រ.បក ចុះថ្ងៃទី ១២ ខែ មិថុនា ឆ្នាំ ២០០០ ស្តីពីការកែសំរួលអនុក្រឹត្យលេខ ៥២ អនក្រ.បក ស្តីពីការបង្កើតរដ្ឋាករទឹកស្វយ័តក្រុងភ្នំពេញ
- យោងតាមសំណើរបស់ប្រតិភូរាជរដ្ឋាភិបាលទទួលបន្ទុកអភិបាលរាជធានីភ្នំពេញ

## សំរេច

**មាត្រា ១ :** ត្រូវបានតែងតាំងលោក **ហុង ស៊ីលីន** អនុប្រធាននាយកដ្ឋានរដ្ឋបាលទូទៅ នៃអគ្គនាយកដ្ឋានរដ្ឋបាល ក្រសួងមហាផ្ទៃ ជាសមាជិកក្រុមប្រឹក្សាភិបាល អាណត្តិទី ២ នៃរដ្ឋាករទឹកស្វយ័តក្រុងភ្នំពេញ ជំនួសលោក **ថោង ម៉ុនធឿន** ដែលបានទទួលមរណភាព ។

**មាត្រា ២ :** រដ្ឋមន្ត្រីទទួលបន្ទុកទីស្តីការគណៈរដ្ឋមន្ត្រី រដ្ឋមន្ត្រីក្រសួងសេដ្ឋកិច្ច និង ហិរញ្ញវត្ថុ ប្រតិភូរាជរដ្ឋាភិបាលទទួលបន្ទុកអភិបាលរាជធានីភ្នំពេញ សហរដ្ឋមន្ត្រី រដ្ឋមន្ត្រី រដ្ឋលេខាធិការ គ្រប់ក្រសួងស្ថាប័នពាក់ព័ន្ធ និងសាមីខ្លួន ត្រូវអនុវត្តអនុក្រឹត្យនេះ ចាប់ពីថ្ងៃចុះហត្ថលេខាតទៅ ៕

*រាជធានីភ្នំពេញ ថ្ងៃទី ១៥ ខែ កក្កដា ឆ្នាំ ២០០២*

**នាយករដ្ឋមន្ត្រី**

**ហ៊ុន សែន**

**កន្លែងទទួល**

- *ក្រសួងព្រះបរមរាជវាំង*
- *អគ្គលេខាធិការដ្ឋានព្រឹទ្ធសភា*
- *អគ្គលេខាធិការដ្ឋានរដ្ឋសភា*
- *ខុទ្ទកាល័យសម្តេចនាយករដ្ឋមន្ត្រី*
- *សាលាក្រុងភ្នំពេញ*
- *រដ្ឋាករទឹកស្វយ័តក្រុងភ្នំពេញ*
- *ដូចមាត្រា ២*
- *ឯកសារ_កាលប្បវត្តិ*

# ព្រះរាជាណាចក្រកម្ពុជា

ជាតិ សាសនា ព្រះមហាក្សត្រ

រាជរដ្ឋាភិបាលកម្ពុជា

លេខ: ៣២៦ អនក្រ.បក

# អនុក្រឹត្យ

ស្តីពី

## ការតែងតាំងក្រុមប្រឹក្សាភិបាល នៃគ្រឹះស្ថានបោះពុម្ពនិងចែកផ្សាយ

### រាជរដ្ឋាភិបាល

- បានឃើញរដ្ឋធម្មនុញ្ញនៃព្រះរាជាណាចក្រកម្ពុជា
- បានឃើញព្រះរាជក្រឹត្យលេខ នស/រកត/១១៩៨/៧២ ចុះថ្ងៃទី ៣០ ខែ វិច្ឆិកា ឆ្នាំ ១៩៩៨ ស្តីពីការតែងតាំងរាជរដ្ឋាភិបាលនៃព្រះរាជាណាចក្រកម្ពុជា
- បានឃើញព្រះរាជក្រមលេខ ០២/នស/៩៤ ចុះថ្ងៃទី ២០ ខែ កក្កដា ឆ្នាំ ១៩៩៤ ដែលប្រកាសអោយប្រើច្បាប់ស្តីពីការរៀបចំ និងការប្រព្រឹត្តទៅ នៃគណៈរដ្ឋមន្ត្រី
- បានឃើញព្រះរាជក្រមលេខ ជស/រកម/០៦៩៦/០៣ ចុះថ្ងៃទី ១៧ ខែ មិថុនា ឆ្នាំ ១៩៩៦ ដែលប្រកាសអោយប្រើច្បាប់ស្តីពី លក្ខន្តិកៈទូទៅនៃសហគ្រាសសាធារណៈ
- បានឃើញអនុក្រឹត្យលេខ ២១អនក្រ.បក ចុះថ្ងៃទី ២៣ ខែ មីនា ឆ្នាំ ១៩៩៨ ស្តីពី ការរៀបចំ និង ការប្រព្រឹត្តទៅរបស់ក្រសួង អប់រំ យុវជន និងកីឡា
- បានឃើញអនុក្រឹត្យលេខ ២៣អនក្រ.បក ចុះថ្ងៃទី ២៥ ខែ មីនា ឆ្នាំ ២០០២ ស្តីពីការបង្កើតគ្រឹះស្ថានបោះពុម្ពនិងចែកផ្សាយ ជាគ្រឹះស្ថានសាធារណៈមានលក្ខណៈសេដ្ឋកិច្ច
- តាមសំណើរបស់រដ្ឋមន្ត្រី ក្រសួងអប់រំ យុវជន និងកីឡា

### សំរេច

**មាត្រា ១:** តែងតាំងសមាសភាពក្រុមប្រឹក្សាភិបាលនៃគ្រឹះស្ថានបោះពុម្ព និងចែកផ្សាយ ដូចមានរាយនាមខាងក្រោម :

| | | | |
|---|---|---|---|
| ១. | លោក អ៊ិន គីមស្រ៊ុន | អគ្គនាយកគ្រឹះស្ថានបោះពុម្ព និងចែកផ្សាយ | ប្រធាន |
| ២. | លោក ចន វណ្ណៈ | អនុប្រធាននាយកដ្ឋាន អប់រំ វប្បធម៌ និង សង្គមកិច្ចនៃទីស្តីការគណៈរដ្ឋមន្ត្រី | សមាជិក |
| ៣. | លោក នេត មុន្នី | អនុប្រធានទី១ នៃនាយកដ្ឋានទ្រព្យសម្បត្តិ រដ្ឋនៃក្រសួងសេដ្ឋកិច្ចនិងហិរញ្ញវត្ថុ | សមាជិក |
| ៤. | ឯកឧត្តម កើ ណៃលាង | អគ្គនាយកនៃអគ្គនាយកដ្ឋានអប់រំ នៃក្រសួងអប់រំយុវជននិងកីឡា | សមាជិក |

មាត្រា២ ៈ រដ្ឋមន្ត្រីទទួលបន្ទុកទីស្តីការគណៈរដ្ឋមន្ត្រី រដ្ឋមន្ត្រីក្រសួងអប់រំ យុវជន និងកីឡា រដ្ឋមន្ត្រីក្រសួងសេដ្ឋកិច្ចនិងហិរញ្ញវត្ថុ រដ្ឋលេខាធិការនៃរដ្ឋលេខាធិការដ្ឋានមុខងារសាធារណៈ រដ្ឋមន្ត្រី រដ្ឋលេខាធិការនៃក្រសួងស្ថាប័នពាក់ព័ន្ធ គ្រឹះស្ថានបោះពុម្ព និងចែកផ្សាយ និងសាមីខ្លួនដែលមានចែងក្នុងមាត្រា១ ត្រូវអនុវត្តអនុក្រឹត្យនេះ ចាប់ពីថ្ងៃចុះហត្ថលេខាតទៅ ។

រាជធានីភ្នំពេញ ថ្ងៃទី០៥ ខែ កក្កដា ឆ្នាំ ២០០២

នាយករដ្ឋមន្ត្រី

ហ៊ុន សែន

**កន្លែងទទួល**

-ក្រសួងព្រះបរមរាជវាំង

-អគ្គលេខាធិការដ្ឋានព្រឹទ្ធសភា

-អគ្គលេខាធិការដ្ឋានរដ្ឋសភា

-ខុទ្ទកាល័យសម្តេចនាយករដ្ឋមន្ត្រី

-ដូចមាត្រា២

-ឯកសារ-កាលប្បវត្តិ

# ព្រះរាជាណាចក្រកម្ពុជា

## ជាតិ សាសនា ព្រះមហាក្សត្រ

**រាជរដ្ឋាភិបាលកម្ពុជា**

លេខៈ ៨៧២ អនក្រ.បក

# អនុក្រឹត្យ

## ស្តីពីការជូនមេដាយស្ថាបនាជាតិ

&&&&&

## រាជរដ្ឋាភិបាល

- បានឃើញរដ្ឋធម្មនុញ្ញ នៃព្រះរាជាណាចក្រកម្ពុជា
- បានឃើញព្រះរាជក្រឹត្យលេខ នស/រកត/១១៩៨/៧២ ចុះថ្ងៃទី ៣០ ខែ វិច្ឆិកា ឆ្នាំ ១៩៩៨ ស្តីពីការតែងតាំងរាជរដ្ឋាភិបាល នៃព្រះរាជាណាចក្រកម្ពុជា
- បានឃើញព្រះរាជក្រមលេខ ០២/នស/៩៤ ចុះថ្ងៃទី ២០ ខែ កក្កដា ឆ្នាំ ១៩៩៤ ដែលប្រកាសអោយប្រើច្បាប់ ស្តីពីការរៀបចំ និងការប្រព្រឹត្តទៅ នៃគណៈរដ្ឋមន្ត្រី
- បានឃើញព្រះរាជក្រឹត្យលេខ ជស/រកត/១០៩៥/០១ ចុះថ្ងៃទី ០៥ ខែ តុលា ឆ្នាំ ១៩៩៥ ស្តីពីការបង្កើត និង ប្រើប្រាស់គ្រឿងឥស្សរិយយស នៃព្រះរាជាណាចក្រកម្ពុជា
- តាមសំណើរបស់អភិបាលខេត្តតាកែវ

## សំរេច

**មាត្រា ១ :** ត្រូវបានបំពាក់ **មេដាយមាសស្ថាបនាជាតិ** ជូនលោក **ចាន់ សុផល** និងអ្នកស្រី **ឡុង លន** ដែលបានបរិច្ចាគធនធានផ្ទាល់ខ្លួនចំនួន ២៣.៥០០ ដុល្លារអាមេរិក ជួយកសាងអគារសិក្សា ០១ ខ្នង និងស្រះទឹក ០១ នៅវត្តអង្គញ្ញ ភូមិប្រាសាទ ឃុំកំពែង ស្រុកគីរីវង់ ខេត្តតាកែវ ។

**មាត្រា ២ :** រដ្ឋមន្ត្រីទទួលបន្ទុកទីស្តីការគណៈរដ្ឋមន្ត្រី និង អភិបាលខេត្តតាកែវ ត្រូវអនុវត្តអនុក្រឹត្យនេះអោយទទួលបានលទ្ធផលល្អ ។

រាជធានីភ្នំពេញ ថ្ងៃទី ៩ ខែ កក្កដា ឆ្នាំ ២០០២

**នាយករដ្ឋមន្ត្រី**

**ហ៊ុន សែន**

**កន្លែងទទួល :**

- ក្រសួងព្រះបរមរាជវាំង
- អគ្គលេខាធិការដ្ឋានព្រឹទ្ធសភា
- អគ្គលេខាធិការដ្ឋានរដ្ឋសភា
- ខុទ្ទកាល័យសម្តេចនាយករដ្ឋមន្ត្រី
- ដូចក្នុងមាត្រា ១ និង មាត្រា ២
- រាជកិច្ច
- ឯកសារ -កាលប្បវត្តិ

# ព្រះរាជាណាចក្រកម្ពុជា

រាជរដ្ឋាភិបាលកម្ពុជា

ជាតិ សាសនា ព្រះមហាក្សត្រ

លេខៈ ៣២៨ អនក្រ.បក

## អនុក្រឹត្យ

## ស្តីពីការជូនមេដាយស្ថាបនាជាតិ

& & & & &

## រាជរដ្ឋាភិបាល

- បានឃើញរដ្ឋធម្មនុញ្ញ នៃព្រះរាជាណាចក្រកម្ពុជា
- បានឃើញព្រះរាជក្រឹត្យលេខ នស/រកត/១១៩៨/៧២ ចុះថ្ងៃទី ៣០ ខែ វិច្ឆិកា ឆ្នាំ ១៩៩៨ ស្តីពីការតែងតាំងរាជរដ្ឋាភិបាល នៃព្រះរាជាណាចក្រកម្ពុជា
- បានឃើញព្រះរាជក្រមលេខ ០២/នស/៩៤ ចុះថ្ងៃទី ២០ ខែ កក្កដា ឆ្នាំ ១៩៩៤ ដែលប្រកាសអោយប្រើច្បាប់ ស្តីពីការរៀបចំ និងការប្រព្រឹត្តទៅ នៃគណៈរដ្ឋមន្ត្រី
- បានឃើញព្រះរាជក្រឹត្យលេខ ជស/រកត/១០៩៥/០១ ចុះថ្ងៃទី ០៥ ខែ តុលា ឆ្នាំ ១៩៩៥ ស្តីពីការបង្កើត និង ប្រើប្រាស់គ្រឿងឥស្សរិយយស នៃព្រះរាជាណាចក្រកម្ពុជា
- តាមសំណើរបស់អភិបាលខេត្តតាកែវ

## សំរេច

**មាត្រា ១** : ត្រូវបានបំពាក់ **មេដាយស្ថាបនាជាតិ** តាមលំដាប់ថ្នាក់ ជូនសប្បុរសជន ដែលបានបរិច្ចាគថវិកាជួយកសាងសមិទ្ធផលនានាក្នុងវត្តអំពិលស្នាង ឃុំលាយបូរ ស្រុកត្រាំកក់ ខេត្តតាកែវ ដូចមាននាមខាងក្រោម ÷

**ក ~ មេដាយមាសស្ថាបនាជាតិ :**

| | | | |
|---|---|---|---|
| ១- ព្រះតេជគុណ | **សម** | **សុន** | ថវិកា ៥៣.០៥៣ USD |
| ២- ព្រះតេជគុណ | **អ៊ិន** | **វន់** | ថវិកា ១២. ៥០០ USD |
| ៣- ឯកឧត្តម | **សម** | **សុផ្លា** | ថវិកា ១១.៨៣០ USD |
| ៤- លោកយាយ | **ជៀវ** | **អេងលី** | ថវិកា ១០. ៤៤០ USD |
| ៥- លោកយាយ | **គង់** | **វ៉ាន់** | ថវិកា ១១. ១៩៧ USD |
| ៦- លោក | **អ៊ិក** | **សម្បត្តិ** | ថវិកា ១១. ០០៣ USD |
| ៧- លោក | **ព្រាប** | **ឈួន** | ថវិកា ១១. ៣៥០ USD |

**ខ ~ មេដាយប្រាក់ស្ថាបនាជាតិ :**

| | | | |
|---|---|---|---|
| - ព្រឹទ្ធាចារ្យ | **ហ៊ុន** | **នាង** | ថវិកា ៥.១០០ USD |

**មាត្រា ២** : រដ្ឋមន្ត្រីទទួលបន្ទុកទីស្តីការគណៈរដ្ឋមន្ត្រី និង អភិបាលខេត្តតាកែវ ត្រូវអនុវត្តអនុក្រឹត្យនេះអោយអោយទទួលបានលទ្ធផលល្អ ។

រាជធានីភ្នំពេញ, ថ្ងៃទី ១៧ ខែ កក្កដា ឆ្នាំ ២០០២

**នាយករដ្ឋមន្ត្រី**

**ហ៊ុន សែន**

**កន្លែងទទួល :**

- ក្រសួងព្រះបរមរាជវាំង
- អគ្គលេខាធិការដ្ឋានព្រឹទ្ធសភា
- អគ្គលេខាធិការដ្ឋានរដ្ឋសភា
- ខុទ្ទកាល័យសម្តេចនាយករដ្ឋមន្ត្រី
- ដូចក្នុងមាត្រា ១ និង មាត្រា ២
- រាជកិច្ច
- ឯកសារ -កាលប្បវត្តិ

# ព្រះរាជាណាចក្រកម្ពុជា

រាជរដ្ឋាភិបាលកម្ពុជា ជាតិ សាសនា ព្រះមហាក្សត្រ

លេខ: [illegible] អនក្រ.បក

## អនុក្រឹត្យ

## ស្តីពីការជូនមេដាយស្ថាបនាជាតិ

& & & & &

## រាជរដ្ឋាភិបាល

- បានឃើញរដ្ឋធម្មនុញ្ញ នៃព្រះរាជាណាចក្រកម្ពុជា
- បានឃើញព្រះរាជក្រឹត្យលេខ នស/រកត/១១៩៨/៧២ ចុះថ្ងៃទី ៣០ ខែ វិច្ឆិកា ឆ្នាំ ១៩៩៨ ស្តីពីការតែងតាំងរាជរដ្ឋាភិបាល នៃព្រះរាជាណាចក្រកម្ពុជា
- បានឃើញព្រះរាជក្រមលេខ ០២/នស/៩៤ ចុះថ្ងៃទី ២០ ខែ កក្កដា ឆ្នាំ ១៩៩៤ ដែលប្រកាសអោយប្រើច្បាប់ ស្តីពីការរៀបចំ និងការប្រព្រឹត្តទៅ នៃគណៈរដ្ឋមន្ត្រី
- បានឃើញព្រះរាជក្រឹត្យលេខ ជស/រកត/១០៩៥/០១ ចុះថ្ងៃទី ០៥ ខែ តុលា ឆ្នាំ ១៩៩៥ ស្តីពីការបង្កើត និង ប្រើប្រាស់គ្រឿងឥស្សរិយយស នៃព្រះរាជាណាចក្រកម្ពុជា
- តាមសំណើរបស់រដ្ឋមន្ត្រីក្រសួងអប់រំ យុវជន និង កីឡា

## សំ រេ ច

**មាត្រា ១:** ត្រូវបានបំពាក់ **មេដាយមាសស្ថាបនាជាតិ** ជូនលោកស្រី **អូសាណៃ មីអិកុ** ប្រធានអង្គការ **JHP** នៃប្រទេសជប៉ុន ដែលបានផ្តល់ថវិកាចំនួន ៣៥.២៦៥ **USD** សំរាប់សាងសង់ អគារសិក្សា ០១ ខ្នង មាន ០៦ បន្ទប់ រួមទាំងសំភារៈ តុ កៅអី អណ្តូងទឹក និង ទោងយោល ជូនសាលាបឋមសិក្សា ០២ ធ្នូ ស្ថិតនៅក្នុងឃុំបរសេដ្ឋ ស្រុកបរសេដ្ឋ ខេត្តកំពង់ស្ពឺ ។

**មាត្រា ២:** រដ្ឋមន្ត្រីទទួលបន្ទុកទីស្តីការគណៈរដ្ឋមន្ត្រី និង រដ្ឋមន្ត្រីក្រសួងអប់រំ យុវជន និង កីឡា ត្រូវអនុវត្តអនុក្រឹត្យនេះ អោយទទួលបានលទ្ធផលល្អ ។

រាជធានីភ្នំពេញ ថ្ងៃទី [illegible] ខែ កក្កដា ឆ្នាំ ២០០២

**នាយករដ្ឋមន្ត្រី**

**ហ៊ុន សែន**

**កន្លែងទទួល :**

- ក្រសួងព្រះបរមរាជវាំង
- អគ្គលេខាធិការដ្ឋានព្រឹទ្ធសភា
- អគ្គលេខាធិការដ្ឋានរដ្ឋសភា
- ខុទ្ទកាល័យសម្តេចនាយករដ្ឋមន្ត្រី
- ដូចក្នុងមាត្រា ១ និង មាត្រា ២
- រាជកិច្ច
- ឯកសារ -កាលប្បវត្តិ

# ព្រះរាជាណាចក្រកម្ពុជា

**រាជរដ្ឋាភិបាលកម្ពុជា** **ជាតិ សាសនា ព្រះមហាក្សត្រ**

លេខ:...៣៣.០...អនក្រ.បក - ៣៣

## អនុក្រឹត្យ

## ស្តីពីការជូនមេដាយស្ថាបនាជាតិ

& & & & &

### រាជរដ្ឋាភិបាល

- បានឃើញរដ្ឋធម្មនុញ្ញ នៃព្រះរាជាណាចក្រកម្ពុជា
- បានឃើញព្រះរាជក្រឹត្យលេខ នស/រកត/១១៩៨/៧២ ចុះថ្ងៃទី ៣០ ខែ វិច្ឆិកា ឆ្នាំ ១៩៩៨ ស្តីពីការតែងតាំងរាជរដ្ឋាភិបាល នៃព្រះរាជាណាចក្រកម្ពុជា
- បានឃើញព្រះរាជក្រមលេខ ០២/នស/៩៤ ចុះថ្ងៃទី ២០ ខែ កក្កដា ឆ្នាំ ១៩៩៤ ដែលប្រកាសអោយប្រើច្បាប់ ស្តីពីការរៀបចំ និងការប្រព្រឹត្តទៅ នៃគណៈរដ្ឋមន្ត្រី
- បានឃើញព្រះរាជក្រឹត្យលេខ ជស/រកត/១០៩៥/០១ ចុះថ្ងៃទី ០៥ ខែ តុលា ឆ្នាំ ១៩៩៥ ស្តីពីការបង្កើត និង ប្រើប្រាស់គ្រឿងឥស្សរិយយស នៃព្រះរាជាណាចក្រកម្ពុជា
- តាមសំណើរបស់អភិបាលខេត្តកណ្តាល

### ស ំ រេ ច

**មាត្រា ១:** ត្រូវបានបំពាក់ **មេដាយស្ថាបនាជាតិ** តាមលំដាប់ថ្នាក់ ជូនសប្បុរសជន ដែលបាន បរិច្ចាគថវិកាជួយកសាងសាលារៀន និង ផ្លូវលំ ក្នុងស្រុកកៀនស្វាយ ខេត្តកណ្តាល ដូចមាននាមខាងក្រោម ÷

**ក- មេដាយមាសស្ថាបនាជាតិ :**

១- ឧកញ៉ា **សៅ សេរីមុន្នី** ថវិកា ១០.០០០ USD

២- លោក **សៅ សុវណ្ណី** ថវិកា ១០.០០០ USD

**ខ- មេដាយសំរិទ្ធស្ថាបនាជាតិ :**

- លោកស្រី **សុខ ជារដ្ឋា** ថវិកា ៣.១០០ USD

**មាត្រា ២:** រដ្ឋមន្ត្រីទទួលបន្ទុកទីស្តីការគណៈរដ្ឋមន្ត្រី និង អភិបាលខេត្តកណ្តាល ត្រូវអនុវត្តអនុក្រឹត្យនេះអោយទទួលបានលទ្ធផលល្អ ។ ៧៨៤៧

រាជធានីភ្នំពេញ ថ្ងៃទី ០៥ ខែ កក្កដា ឆ្នាំ ២០០២

**នាយករដ្ឋមន្ត្រី**

**ហ៊ុន សែន**

**កន្លែងទទួល :**

- ក្រសួងព្រះបរមរាជវាំង
- អគ្គលេខាធិការដ្ឋានព្រឹទ្ធសភា
- អគ្គលេខាធិការដ្ឋានរដ្ឋសភា
- ខុទ្ទកាល័យសម្តេចនាយករដ្ឋមន្ត្រី
- ដូចក្នុងមាត្រា ១ និង មាត្រា ២
- រាជកិច្ច
- ឯកសារ -កាលប្បវត្តិ ✓

# ព្រះរាជាណាចក្រកម្ពុជា

**រាជរដ្ឋាភិបាលកម្ពុជា** **ជាតិ សាសនា ព្រះមហាក្សត្រ**

លេខៈ...៣៣១...អនក្រ.បក

## អនុក្រឹត្យ
## ស្តីពីការជូនមេដាយស្ថាបនាជាតិ

& & & & &

## រាជរដ្ឋាភិបាល

- បានឃើញរដ្ឋធម្មនុញ្ញ នៃព្រះរាជាណាចក្រកម្ពុជា
- បានឃើញព្រះរាជក្រឹត្យលេខ នស/រកត/១១៩៨/៧២ ចុះថ្ងៃទី ៣០ ខែ វិច្ឆិកា ឆ្នាំ ១៩៩៨ ស្តីពីការតែងតាំងរាជរដ្ឋាភិបាល នៃព្រះរាជាណាចក្រកម្ពុជា
- បានឃើញព្រះរាជក្រមលេខ ០២/នស/៩៤ ចុះថ្ងៃទី ២០ ខែ កក្កដា ឆ្នាំ ១៩៩៤ ដែលប្រកាសអោយប្រើច្បាប់ ស្តីពីការរៀបចំ និងការប្រព្រឹត្តទៅ នៃគណៈរដ្ឋមន្ត្រី
- បានឃើញព្រះរាជក្រឹត្យលេខ ជស/រកត/១០៩៥/០១ ចុះថ្ងៃទី ០៥ ខែ តុលា ឆ្នាំ ១៩៩៥ ស្តីពីការបង្កើត និង ប្រើប្រាស់គ្រឿងឥស្សរិយយស នៃព្រះរាជាណាចក្រកម្ពុជា
- តាមសំណើរបស់អភិបាលខេត្តកណ្តាល

## ស ំ រ េ ច

**មាត្រា ១ៈ** ត្រូវបានបំពាក់ **មេដាយមាសស្ថាបនាជាតិ** ជូនសប្បុរសជន ០៤ រូប ដែលបានបរិច្ចាគថវិកាជួយកសាងមណ្ឌលកុមារកំព្រា ចំនួន ១៣ ខ្នង ស្ថិតក្នុងឃុំបឹងខ្យាង ស្រុកកណ្តាលស្ទឹង ខេត្តកណ្តាល ដូចមានឈ្មោះខាងក្រោម ÷

១- លោក **ZANNIER** ប្រធាន **FONDATION ZANNIER HOLYBABY**
ថវិកា ៣៥.២០០ USD

២- លោកស្រី **មាស យ៉ាន្ធូរ៉ែត្រ** អគ្គនាយក **FONDATION ZANNIER HOLYBABY**
ថវិកា ១២.៣២០ USD

៣- លោក **Dr. HOURTOULLE PASCAL** ថវិកា ១២.១៥០ USD

៤ - លោកវេជ្ជ. **កែវ សាន** ថវិកា ១១.០៥០ USD

**មាត្រា ២ៈ** រដ្ឋមន្ត្រីទទួលបន្ទុកទីស្តីការគណៈរដ្ឋមន្ត្រី និង អភិបាលខេត្តកណ្តាល ត្រូវអនុវត្តអនុក្រឹត្យនេះអោយទទួលបានលទ្ធផលល្អ

រាជធានីភ្នំពេញ ថ្ងៃទី ១២ ខែ កក្កដា ឆ្នាំ ២០០២

**នាយករដ្ឋមន្ត្រី**

**ហ៊ុន សែន**

**កន្លែងទទួល :**

- ក្រសួងព្រះបរមរាជវាំង
- អគ្គលេខាធិការដ្ឋានព្រឹទ្ធសភា
- អគ្គលេខាធិការដ្ឋានរដ្ឋសភា
- ខុទ្ទកាល័យសម្តេចនាយករដ្ឋមន្ត្រី
- ដូចក្នុងមាត្រា ១ និង មាត្រា ២
- រាជកិច្ច
- ឯកសារ -កាលប្បវត្តិ

# ព្រះរាជាណាចក្រកម្ពុជា

**រាជរដ្ឋាភិបាលកម្ពុជា** **ជាតិ សាសនា ព្រះមហាក្សត្រ**

លេខៈ ៣៣ អនក្រ.បក

## អនុក្រឹត្យ
## ស្តីពីការជូនមេដាយស្ថាបនាជាតិ

ៜៜៜៜៜ

## រាជរដ្ឋាភិបាល

- បានឃើញរដ្ឋធម្មនុញ្ញ នៃព្រះរាជាណាចក្រកម្ពុជា
- បានឃើញព្រះរាជក្រឹត្យលេខ នស/រកត/១១៩៨/៧២ ចុះថ្ងៃទី ៣០ ខែវិច្ឆិកា ឆ្នាំ ១៩៩៨ ស្តីពីការតែងតាំងរាជរដ្ឋាភិបាល នៃព្រះរាជាណាចក្រកម្ពុជា
- បានឃើញព្រះរាជក្រមលេខ ០២/នស/៩៤ ចុះថ្ងៃទី ២០ ខែ កក្កដា ឆ្នាំ ១៩៩៤ ដែលប្រកាសអោយប្រើច្បាប់ ស្តីពីការរៀបចំ និងការប្រព្រឹត្តទៅនៃគណៈរដ្ឋមន្ត្រី
- បានឃើញព្រះរាជក្រឹត្យលេខ ជស / រកត / ១០៩៥ /០១ ចុះថ្ងៃទី ០៥ ខែ តុលា ឆ្នាំ ១៩៩៥ ស្តីពីការបង្កើត និងប្រើប្រាស់គ្រឿងឥស្សរិយយស នៃព្រះរាជាណាចក្រកម្ពុជា
- តាមសំណើរបស់រដ្ឋមន្ត្រីក្រសួងធម្មការ និង សាសនា

## សំរេច

**មាត្រា ១ :** ត្រូវបានបំពាក់ **មេដាយមាសស្ថាបនាជាតិ** ជូនសប្បុរសជន ០២ រូប ដែលបានបរិច្ចាគធនធានផ្ទាល់ខ្លួនជួយកសាងព្រះវិហារ វត្តទួលសម្មាធិ និង ធ្វើផ្លូវលំ ០១ ខ្សែ ចូលទៅកាន់វត្ត នៅក្នុងស្រុកពាមរក៍ ខេត្តព្រៃវែង ចំណាយអស់ថវិកា ២៣.៩៧០ ដុល្លារអាមេរិក ដូចមានរាយនាមខាងក្រោមនេះ ÷

១ - លោក **សន សូរុន**

២ - លោកស្រី **តាំង ឆេង**

**មាត្រា ២ :** រដ្ឋមន្ត្រីទទួលបន្ទុកទីស្តីការគណៈរដ្ឋមន្ត្រី រដ្ឋមន្ត្រីក្រសួងធម្មការ និង សាសនា និង អភិបាលខេត្តព្រៃវែង ត្រូវអនុវត្តអនុក្រឹត្យនេះអោយទទួលបានលទ្ធផលល្អ ។

រាជធានីភ្នំពេញ, ថ្ងៃទី ០៩ ខែ កក្កដា ឆ្នាំ ២០០២

**នាយករដ្ឋមន្ត្រី**

**ហ៊ុន សែន**

**កន្លែងទទួល :**

- ក្រសួងព្រះបរមរាជវាំង
- អគ្គលេខាធិការដ្ឋានព្រឹទ្ធសភា
- អគ្គលេខាធិការដ្ឋានរដ្ឋសភា
- ខុទ្ទកាល័យសម្តេចនាយករដ្ឋមន្ត្រី
- ដូចក្នុងមាត្រា១ និង មាត្រា ២
- រាជកិច្ច
- កាលប្បវត្តិ - ឯកសារ

**ព្រះរាជាណាចក្រកម្ពុជា**

**ជាតិ សាសនា ព្រះមហាក្សត្រ**

**រាជរដ្ឋាភិបាលកម្ពុជា**

**លេខៈ** ៣៨ សសរ

# សេចក្តីសំរេច

## ស្តីពី

## ការបន្ថែមសមាសភាព ក្នុងក្រុមការងារ ដើម្បីរៀបចំឯកសារគតិយុត្តិ និងពិនិត្យដោះស្រាយ ចំពោះគំរោងជួល និងអភិវឌ្ឍន៍កោះរុង និងកោះរុងសន្លឹម របស់ក្រុមហ៊ុន ISLAND DEVELOPMENT GROUP INC.

## រាជរដ្ឋាភិបាល

- បានឃើញរដ្ឋធម្មនុញ្ញ នៃព្រះរាជាណាចក្រកម្ពុជា ឆ្នាំ ១៩៩៣
- បានឃើញព្រះរាជក្រឹត្យលេខ នស/រកត/១១៩៨/៧២ ចុះថ្ងៃទី ៣០ ខែ វិច្ឆិកា ឆ្នាំ ១៩៩៨ ស្តីពីការតែងតាំងរាជរដ្ឋាភិបាល នៃព្រះរាជាណាចក្រកម្ពុជា
- បានឃើញព្រះរាជក្រមលេខ ០២/នស/៩៤ ចុះថ្ងៃទី ២០ ខែ កក្កដា ឆ្នាំ ១៩៩៤ ដែលប្រកាសអោយប្រើច្បាប់ ស្តីពីការរៀបចំ និងការប្រព្រឹត្តទៅ នៃគណៈរដ្ឋមន្ត្រី
- បានឃើញព្រះរាជក្រមលេខ ០៣/នស/៩៤ ចុះថ្ងៃទី ០៥ ខែ សីហា ឆ្នាំ១៩៩៤ ដែលប្រកាសអោយប្រើច្បាប់ ស្តីពីវិនិយោគ នៃព្រះរាជាណាចក្រកម្ពុជា
- យោងអនុក្រឹត្យលេខ ៧០ អនក្រ.បក ចុះថ្ងៃទី ២៧ ខែ កក្កដា ឆ្នាំ ២០០១ ស្តីពីការរៀបចំ និងការប្រព្រឹត្តទៅ នៃក្រុមប្រឹក្សាអភិវឌ្ឍន៍កម្ពុជា
- យោងអនុក្រឹត្យលេខ ៨៨ អនក្រ.បក ចុះថ្ងៃទី ២៩ ខែ ធ្នូ ឆ្នាំ ១៩៩៧ ស្តីពីការអនុវត្តន៍ច្បាប់វិនិយោគ នៃព្រះរាជាណាចក្រកម្ពុជា
- យោងអនុក្រឹត្យលេខ ៥៣ អនក្រ.បក ចុះថ្ងៃទី ១១ ខែ មិថុនា ឆ្នាំ ១៩៩៩ ស្តីពីការធ្វើវិសោធនកម្មលើអនុក្រឹត្យលេខ ៨៨ អនក្រ.បក ចុះថ្ងៃទី ២៩ ខែ ធ្នូ ឆ្នាំ ១៩៩៧
- យោងសេចក្តីសំរេចលេខ ២៩ សសរ ចុះថ្ងៃទី ១៦ ខែ ឧសភា ឆ្នាំ ២០០២ ស្តីពីការបង្កើតក្រុមការងារ ដើម្បីរៀបចំឯកសារគតិយុត្តិ និងពិនិត្យដោះស្រាយ ចំពោះគំរោងជួល និងអភិវឌ្ឍន៍កោះរុង និងកោះរុងសន្លឹម របស់ក្រុមហ៊ុន **ISLAND DEVELOPMENT GROUP INC.**
- អនុលោមតាមតំរូវការចាំបាច់

# សំរេច

**ប្រការ១:** បន្ថែមសមាសភាព កងយោធពលខេមរភូមិន្ទ ជាសមាជិកក្នុងក្រុមការងារ ដើម្បីរៀបចំឯកសារគតិយុត្តិ និងពិនិត្យដោះស្រាយ ចំពោះគំរោងជួល និងអភិវឌ្ឍន៍កោះរុង និងកោះរុងសន្លឹម ដូចមានរាយនាមខាងក្រោម :

១- ឯកឧត្តមនាយឧត្តមសេនីយ៍ **ម៉ុល សារឿន** អគ្គមេបញ្ជាការរង និងជានាយសេនាធិការចំរុះ សមាជិក

២- លោក ឧត្តមនាវីត្រី **អ៊ុក សីហា** មេបញ្ជាការមូលដ្ឋានសមុទ្រ សមាជិក

៣- លោក វរនាវីឯក **គ្រួច គឹមថុន** នាយការិយាល័យទី៣ បញ្ជាការដ្ឋានជើងទឹក សមាជិក

៤- លោក វរនាវីទោ **ឃុន បូរិន្ទ** មេបញ្ជាការរងមូលដ្ឋានសមុទ្រ សមាជិក

**ប្រការ២:** ក្រៅពីការបន្ថែមសមាសភាព ដូចមានចែងក្នុងប្រការ១ ខាងលើ ខ្លឹមសារនៃសេចក្ដីសំរេចលេខ ២៩ សសរ ចុះថ្ងៃទី ១៦ ខែ ឧសភា ឆ្នាំ ២០០២ នៅរក្សាទុកជាធរមានដដែល ។

**ប្រការ៣:** រដ្ឋមន្ត្រីទទួលបន្ទុកទីស្ដីការគណៈរដ្ឋមន្ត្រី - សហរដ្ឋមន្ត្រីក្រសួងក្រសួងមហាផ្ទៃ - សហរដ្ឋមន្ត្រីក្រសួងការពារជាតិ - រដ្ឋមន្ត្រីក្រសួងសេដ្ឋកិច្ច និងហិរញ្ញវត្ថុ - រដ្ឋមន្ត្រីក្រសួងទេសចរណ៍ - រដ្ឋមន្ត្រីក្រសួងរៀបចំដែនដី នគរូបនីយកម្ម និងសំណង់ - រដ្ឋមន្ត្រីក្រសួងសាធារណការ និងដឹកជញ្ជូន - រដ្ឋមន្ត្រីក្រសួងកសិកម្ម រុក្ខាប្រមាញ់ និងនេសាទ - រដ្ឋមន្ត្រីក្រសួងបរិស្ថាន - ប្រធាន"ក.អ.ក" - រដ្ឋមន្ត្រីគ្រប់ក្រសួង - ប្រធានគ្រប់ស្ថាប័នដែលពាក់ព័ន្ធ និងសាមីខ្លួនដូចមានចែងក្នុងប្រការ១ ត្រូវអនុវត្តសេចក្ដីសំរេចនេះតាមភារកិច្ចរៀងៗខ្លួនអោយមានប្រសិទ្ធភាពខ្ពស់ ចាប់ពីថ្ងៃចុះហត្ថលេខាតទៅ ។

រាជធានីភ្នំពេញ ថ្ងៃទី [illegible] ខែ មិថុនា ឆ្នាំ ២០០២

នាយករដ្ឋមន្ត្រី

ហ៊ុន សែន

កន្លែងទទួល
- ក្រសួងព្រះបរមរាជវាំង
- អគ្គលេខាធិការដ្ឋានព្រឹទ្ធសភា
- អគ្គលេខាធិការដ្ឋានរដ្ឋសភា
- ខុទ្ទកាល័យសម្ដេចនាយករដ្ឋមន្ត្រី
- ដូចប្រការ ៣
- ឯកសារ-កាលប្បវត្តិ

ព្រះរាជាណាចក្រកម្ពុជា

ជាតិ សាសនា ព្រះមហាក្សត្រ

រាជរដ្ឋាភិបាលកម្ពុជា

លេខៈ ៣៧ សសរ

# សេចក្តីសំរេច

## ស្តីពី

## ការបន្ថែមសមាសភាព ក្នុងក្រុមការងារ ដើម្បីរៀបចំឯកសារគតិយុត្តិ និងពិនិត្យដោះស្រាយ ចំពោះគំរោងជួល និងអភិវឌ្ឍន៍កោះរុង និងកោះរុងសន្លឹម របស់ក្រុមហ៊ុន ISLAND DEVELOPMENT GROUP INC.

## រាជរដ្ឋាភិបាល

- បានឃើញរដ្ឋធម្មនុញ្ញ នៃព្រះរាជាណាចក្រកម្ពុជា ឆ្នាំ ១៩៩៣
- បានឃើញព្រះរាជក្រឹត្យលេខ នស/រកត/១១៩៨/៧២ ចុះថ្ងៃទី ៣០ ខែ វិច្ឆិកា ឆ្នាំ ១៩៩៨ ស្តីពីការតែងតាំងរាជរដ្ឋាភិបាល នៃព្រះរាជាណាចក្រកម្ពុជា
- បានឃើញព្រះរាជក្រមលេខ ០២/នស/៩៤ ចុះថ្ងៃទី ២០ ខែ កក្កដា ឆ្នាំ ១៩៩៤ ដែលប្រកាសអោយប្រើច្បាប់ ស្តីពីការរៀបចំ និងការប្រព្រឹត្តទៅ នៃគណៈរដ្ឋមន្ត្រី
- បានឃើញព្រះរាជក្រមលេខ ០៣/នស/៩៤ ចុះថ្ងៃទី ០៥ ខែ សីហា ឆ្នាំ១៩៩៤ ដែលប្រកាសអោយប្រើច្បាប់ ស្តីពីវិនិយោគ នៃព្រះរាជាណាចក្រកម្ពុជា
- យោងអនុក្រឹត្យលេខ ៧០ អនក្រ.បក ចុះថ្ងៃទី ២៧ ខែ កក្កដា ឆ្នាំ ២០០១ ស្តីពីការរៀបចំ និងការប្រព្រឹត្តទៅ នៃក្រុមប្រឹក្សាអភិវឌ្ឍន៍កម្ពុជា
- យោងអនុក្រឹត្យលេខ ៨៨ អនក្រ.បក ចុះថ្ងៃទី ២៩ ខែ ធ្នូ ឆ្នាំ ១៩៩៧ ស្តីពីការអនុវត្តន៍ច្បាប់វិនិយោគ នៃព្រះរាជាណាចក្រកម្ពុជា
- យោងអនុក្រឹត្យលេខ ៥៣ អនក្រ.បក ចុះថ្ងៃទី ១១ ខែ មិថុនា ឆ្នាំ ១៩៩៩ ស្តីពីការធ្វើវិសោធនកម្មលើអនុក្រឹត្យលេខ ៨៨ អនក្រ.បក ចុះថ្ងៃទី ២៩ ខែ ធ្នូ ឆ្នាំ ១៩៩៧
- យោងសេចក្តីសំរេចលេខ ២៩ សសរ ចុះថ្ងៃទី ១៦ ខែ ឧសភា ឆ្នាំ ២០០២ ស្តីពីការបង្កើតក្រុមការងារ ដើម្បីរៀបចំឯកសារគតិយុត្តិ និងពិនិត្យដោះស្រាយ ចំពោះគំរោងជួល និងអភិវឌ្ឍន៍កោះរុង និងកោះរុងសន្លឹម របស់ក្រុមហ៊ុន **ISLAND DEVELOPMENT GROUP INC.**
- យោងសេចក្តីសំរេចលេខ ៣៦ សសរ ចុះថ្ងៃទី ២៨ ខែ មិថុនា ឆ្នាំ ២០០២ ស្តីពីការបន្ថែមសមាសភាព ក្នុងក្រុមការងារ ដើម្បីរៀបចំឯកសារគតិយុត្តិ និងពិនិត្យដោះស្រាយ ចំពោះគំរោងជួល និងអភិវឌ្ឍន៍កោះរុង និងកោះរុងសន្លឹម របស់ក្រុមហ៊ុន **ISLAND DEVELOPMENT GROUP INC.**
- អនុលោមតាមតំរូវការចាំបាច់

ឃ

# សម្រេច

**ប្រការ១ៈ** បន្ថែមសមាសភាព ឯកឧត្តម **ព្រុំ សុខា** រដ្ឋលេខាធិការក្រសួងមហាផ្ទៃ ជាសមាជិក ០១រូបទៀត ក្នុងក្រុមការងារដើម្បីរៀបចំឯកសារគតិយុត្តិ និងពិនិត្យដោះស្រាយ ចំពោះគំរោងជួល និងអភិវឌ្ឍន៍កោះរុង និងកោះរុងសន្លឹម ។

**ប្រការ២ៈ** ក្រៅពីការបន្ថែមសមាសភាព ដូចមានចែងក្នុងប្រការ១ ខាងលើ ខ្លឹមសារនៃសេចក្តីសំរេចលេខ ២៩ សសរ ចុះថ្ងៃទី ១៦ ខែ ឧសភា ឆ្នាំ ២០០២ និងសេចក្តីសំរេចលេខ ៣៦ សសរ ចុះថ្ងៃទី ២៨ ខែ មិថុនា ឆ្នាំ ២០០២ នៅរក្សាទុកជាធរមានដដែល ។

**ប្រការ៣ៈ** រដ្ឋមន្ត្រីទទួលបន្ទុកទីស្តីការគណៈរដ្ឋមន្ត្រី - សហរដ្ឋមន្ត្រីក្រសួងមហាផ្ទៃ - សហរដ្ឋមន្ត្រីក្រសួងការពារជាតិ - រដ្ឋមន្ត្រីក្រសួងសេដ្ឋកិច្ច និងហិរញ្ញវត្ថុ - រដ្ឋមន្ត្រីក្រសួងទេសចរណ៍ - រដ្ឋមន្ត្រីក្រសួងរៀបចំដែនដី នគរូបនីយកម្ម និងសំណង់ - រដ្ឋមន្ត្រីក្រសួងសាធារណការ និងដឹកជញ្ជូន - រដ្ឋមន្ត្រីក្រសួងកសិកម្មរុក្ខាប្រមាញ់ និងនេសាទ - រដ្ឋមន្ត្រីក្រសួងបរិស្ថាន -ប្រធាន "ក.អ.ក" - រដ្ឋមន្ត្រីគ្រប់ក្រសួង -ប្រធានគ្រប់ស្ថាប័នដែលពាក់ព័ន្ធ និងសាមីខ្លួនដូចមានចែងក្នុងប្រការ ១ ត្រូវអនុវត្តសេចក្តីសំរេចនេះតាមភារកិច្ចរៀងៗខ្លួនអោយមានប្រសិទ្ធភាពខ្ពស់ ចាប់ពីថ្ងៃចុះហត្ថលេខាតទៅ ។

រាជធានីភ្នំពេញ ថ្ងៃទី ១៧ ខែ កក្កដា ឆ្នាំ ២០០២

នាយករដ្ឋមន្ត្រី

ហ៊ុន សែន

**កន្លែងទទួល**

- ក្រសួងព្រះបរមរាជវាំង
- អគ្គលេខាធិការដ្ឋានព្រឹទ្ធសភា
- អគ្គលេខាធិការដ្ឋានរដ្ឋសភា
- ខុទ្ទកាល័យសម្តេចនាយករដ្ឋមន្ត្រី
- ដូចប្រការ ៣
- ឯកសារ-កាលប្បវត្តិ ✓

**ព្រះរាជាណាចក្រកម្ពុជា**

**ជាតិ សាសនា ព្រះមហាក្សត្រ**

**រាជរដ្ឋាភិបាលកម្ពុជា**

លេខ:..០៩.......សរណន

# សារាចរណែនាំ

## ស្តីពី

## ការប្រារព្ធទិវាអក្ខរកម្មជាតិ ៨ កញ្ញា

ក្នុងស្មារតីបំផុសចលនាអក្ខរកម្មអោយបានជ្រួតជ្រាបដល់គ្រប់ក្រសួង ស្ថាប័នរដ្ឋ ឯកជន ព្រមទាំងប្រជាពលរដ្ឋក្នុងទូទាំងប្រទេស ស្របតាមសេចក្តីសំរេចចិត្តនៃមហាសន្និបាតអង្គការសហប្រជាជាតិ លេខ ៥៦/១១៦ ចុះថ្ងៃទី១៨ ខែមករា ឆ្នាំ២០០២ ស្តីពី *"ទសវត្សអង្គការសហប្រជាជាតិសំរាប់អក្ខរកម្ម និងការអប់រំសំរាប់ទាំងអស់គ្នា"* និងតាមស្មារតីនៃព្រះរាជក្រឹត្យ លេខ នស.រកត ០៩០០/១៦៣ ចុះថ្ងៃទី ៧ ខែ កញ្ញា ឆ្នាំ ២០០០ ស្តីពីការកំណត់យកថ្ងៃទី ៨ ខែ កញ្ញា ឆ្នាំ ២០០២ ជាទិវាអក្ខរកម្មជាតិនោះ រាជរដ្ឋាភិបាលកម្ពុជា ចេញសេចក្តីណែនាំដល់គ្រប់ក្រសួង ស្ថាប័ន ខេត្ត-ក្រុង អោយរៀបចំប្រារព្ធទិវា អក្ខរកម្មជាតិថ្ងៃទី ៨ ខែកញ្ញា ឆ្នាំ២០០២ ក្រោមប្រធានបទ *"អនក្ខរជនទប់ទល់នឹងជម្ងឺអេដស៍"* ដែលមានខ្លឹមសារ ណែនាំដូចខាងក្រោម :

១- ក្រសួងអប់រំ យុវជន និង កីឡា ត្រូវរៀបចំការប្រជុំថ្នាក់ជាតិនៅកន្លែងណាមួយនាថ្ងៃទី ៨ ខែ កញ្ញា ឆ្នាំ ២០០២ ដើម្បីផ្សព្វផ្សាយលទ្ធផលអក្ខរកម្មនាឆ្នាំកន្លងមក និងប្រកាសអំពីផែនការយុទ្ធសាស្ត្រសំខាន់ៗ នៃការងារអប់រំក្រៅប្រព័ន្ធ ដែលត្រូវអនុវត្តនាពេលខាងមុខ ដោយមានការចូលរួមពីក្រសួង ស្ថាប័ន អាជ្ញាធរដែនដី អង្គការជាតិ និង អន្តរជាតិ សិស្ស និស្សិត និងប្រជាពលរដ្ឋ ។

២- អាជ្ញាធរដែនដីគ្រប់លំដាប់ថ្នាក់ត្រូវចាត់ចែងរៀបចំ :

ក- បិទបដា ពាក្យស្លោក នៅតាមអង្គភាពរដ្ឋ ទីប្រជុំជន ដងផ្លូវសាធារណៈ ចាប់ពីថ្ងៃទី ៧ ដល់ថ្ងៃទី ៩ ខែ កញ្ញា ឆ្នាំ ២០០២ ។

ខ- ធ្វើមិទ្ទិញ ឬ ប្រជុំ ឬហែរក្បួន ដែលមានខ្លឹមសារពាក់ព័ន្ធទៅនឹងការបំផុសចលនាអក្ខរកម្ម និងការប្រយុទ្ធប្រឆាំងនឹងជម្ងឺអេដស៍ ។

គ- ត្រូវរៀបចំបំផុសចលនា និងធ្វើការប្រឡងសិស្សអក្ខរកម្មតាមប្រធានបទ *"អនក្ខរជនទប់ទល់នឹងជម្ងឺអេដស៍"* តាមល័ក្ខខ័ណ្ឌដូចខាងក្រោម :

- ចំពោះទីកន្លែងដែលមានថ្នាក់រៀនអក្ខរកម្ម ត្រូវចាត់ចែងប្រឡងសិស្សអក្ខរកម្មដើម្បីស្វែងយល់អំពីជម្ងឺអេដស៍ ហើយបេក្ខជនដែលទទួលបានពិន្ទុល្អក្នុងការប្រឡងត្រូវចាត់ចែងជូនរង្វាន់លើកទឹកចិត្តតាមការជាក់ស្តែង ។
- ចំពោះទីកន្លែងដែលពុំមានថ្នាក់រៀនអក្ខរកម្ម ត្រូវចាត់ចែងមន្ត្រីជំនាញឱ្យចុះឃោសនាអំពីសារសំខាន់នៃការរៀនសូត្រ និងគ្រោះថ្នាក់នៃជម្ងឺអេដស៍ ។

៣- ក្រសួងធម្មការ និង សាសនា ត្រូវណែនាំដល់ព្រះសង្ឃ និងពុទ្ធបរិស័ទអោយមានសទ្ធាជ្រះថ្លាក្នុងការជួយឧបត្ថម្ភដល់ការងារអក្ខរកម្ម និង ពន្យល់ណែនាំដល់អនក្ខរជនអោយយល់អំពីសារៈសំខាន់នៃការរៀនសូត្រ។

៤- ក្រសួងពត៌មាន និងក្រសួងវប្បធម៌ និងវិចិត្រសិល្បៈ ត្រូវពិនិត្យលទ្ធភាពរៀបចំការសំដែងសិល្បៈ បទអត្ថាធិប្បាយ បទយកការណ៍ ស្តីពីការងារអប់រំក្រៅប្រព័ន្ធនៅកម្ពុជា ផ្សព្វផ្សាយតាមវិទ្យុ និងទូរទស្សន៍។

៥- អង្គការអន្តរជាតិ និងអង្គការក្រៅរដ្ឋាភិបាលនានា ដែលកំពុងបំពេញការងារអប់រំក្រៅប្រព័ន្ធនៅកម្ពុជា សូមជួយឧបត្ថម្ភដល់ពិធីបុណ្យនេះនៅតាមទីកន្លែងដែលអង្គការនោះប្រតិបត្តិ និងត្រូវធ្វើរបាយការណ៍ពីសកម្មភាពរបស់អង្គការផ្ញើទៅក្រសួងអប់រំ យុវជន និងកីឡា អោយបានមុនដំណាច់ខែ សីហា ២០០២។

៦- គណៈកម្មាធិការអប់រំសំរាប់ទាំងអស់គ្នានៅគ្រប់លំដាប់ថ្នាក់ ត្រូវប្រជុំបូកសរុបវាយតំលៃការងារអប់រំក្រៅប្រព័ន្ធ ដែលបានអនុវត្តកន្លងមក និងលើកទិសដៅឆ្នាំខាងមុខ។

ទទួលបានសារាចរណែនាំនេះ សូមឯកឧត្តម លោកជំទាវ លោក លោកស្រី ថ្នាក់ដឹកនាំគ្រប់ក្រសួង-ស្ថាប័នដែលពាក់ព័ន្ធ អភិបាលខេត្ត-ក្រុង ផ្សព្វផ្សាយ និងរៀបចំណែនាំ ព្រមទាំងអនុវត្តសារាចរនេះអោយទទួលបានលទ្ធផលល្អប្រសើរ រួចហើយត្រូវធ្វើរបាយការណ៍ស្តីពីលទ្ធផលនៃការរៀបចំពិធីនេះ ផ្ញើមកក្រសួងអប់រំ យុវជន និង កីឡា ដើម្បីបូកសរុបជូនគណៈរដ្ឋមន្ត្រីអោយបានមុនដំណាច់ខែ កញ្ញា ឆ្នាំ ២០០២។

រាជធានីភ្នំពេញ ថ្ងៃទី ០៥ ខែកក្កដា ឆ្នាំ ២០០២

នាយករដ្ឋមន្ត្រី

ហ៊ុន សែន

**កន្លែងទទួល**

- ក្រសួងព្រះបរមរាជវាំង
- អគ្គលេខាធិការដ្ឋានព្រឹទ្ធសភា
- អគ្គលេខាធិការដ្ឋានរដ្ឋសភា
- ខុទ្ទកាល័យសម្តេចនាយករដ្ឋមន្ត្រី

"ដើម្បីទូលថ្វាយ និង គោរពជូនជ្រាបជាពត៌មាន"

- គ្រប់ក្រសួង ស្ថាប័ននានា
- គ្រប់អភិបាលខេត្ត-ក្រុង

"ដើម្បីអនុវត្ត"

- កាលប្បវត្តិ-ឯកសារ

ព្រះរាជាណាចក្រកម្ពុជា
ជាតិ សាសនា ព្រះមហាក្សត្រ

ក្រសួងសេដ្ឋកិច្ច និង ហិរញ្ញវត្ថុ
ក្រសួងឧស្សាហកម្ម រ៉ែនិងថាមពល
លេខ : ៤១៤ សហវ

ភ្នំពេញ ថ្ងៃទី ០១ ខែ កក្កដា ឆ្នាំ ២០០២

# ប្រកាស
## របស់ក្រសួងសេដ្ឋកិច្ច និង ហិរញ្ញវត្ថុ
## និងក្រសួងឧស្សាហកម្ម រ៉ែនិងថាមពល
## ស្តីពី
## ការរំលាយចោលកិច្ចសន្យាជួលរោងចក្រយន្តសាស្ត្រទី៦

✻✻✻✻✻✻✻✻✻✻✻

១-បានឃើញរដ្ឋធម្មនុញ្ញនៃព្រះរាជាណាចក្រកម្ពុជាឆ្នាំ១៩៩៣

២-បានឃើញព្រះរាជក្រឹត្យលេខ នស/រ.ក.ត/១១៩៨/៧២ ចុះថ្ងៃទី៣០ ខែវិច្ឆិកា ឆ្នាំ១៩៩៨ ស្តីពីការតែងតាំងរាជរដ្ឋាភិបាលនៃព្រះរាជាណាចក្រកម្ពុជា

៣-បានឃើញច្បាប់ស្តីពីហិរញ្ញវត្ថុសំរាប់ការគ្រប់គ្រងឆ្នាំ២០០០ដែលប្រកាសឱ្យប្រើដោយព្រះរាជក្រមលេខនស/រកម/១២៩៩/១៥ ចុះថ្ងៃទី២៥ ខែធ្នូ ឆ្នាំ១៩៩៩

៤-បានឃើញអនុក្រឹត្យលេខ០៤/អនក្រ/បក ចុះថ្ងៃទី២០ ខែមករាឆ្នាំ២០០០ ស្តីពីការរៀបចំ និងការប្រព្រឹត្តិទៅនៃក្រសួងសេដ្ឋកិច្ច និង ហិរញ្ញវត្ថុ

៥-បានឃើញអនុក្រឹត្យលេខ៣៥ /អនក្រ/បកចុះថ្ងៃទី២៦ ខែមេសា ឆ្នាំ១៩៩៩ ស្តីពីការរៀបចំ និងការប្រព្រឹត្តិទៅនៃក្រសួងឧស្សាហកម្ម រ៉ែនិងថាមពល

៦-យោងកិច្ចសន្យាជួលរោងចក្រយន្តសាស្ត្រទី៦ ចុះថ្ងៃទី១៤ ខែតុលា ឆ្នាំ១៩៩៤

៧-យោងលិខិតលេខ ១.៨៧៥ សហវ.ទរ ចុះថ្ងៃទី០៦ ខែឧសភា ឆ្នាំ២០០២ របស់ក្រសួងសេដ្ឋកិច្ច និងហិរញ្ញវត្ថុ

## សំរេច :

**ប្រការ១** : រំលាយចោលកិច្ចសន្យាជួលរោងចក្រយន្តសាស្ត្រទី៦ចុះថ្ងៃទី១៤ ខែតុលា ឆ្នាំ១៩៩៤ និងដកហូតទីតាំងរោងចក្រយន្តសាស្ត្រទី៦ដែលស្ថិតនៅតាមដងផ្លូវជាតិលេខ ៥ "គីឡូម៉ែត្រលេខ៦" ពីលោក EWE SWEE KHENG តំណាងក្រុមហ៊ុន CAMBODIA WINERY PRIVATE LTD ដោយមូលហេតុមិនគោរពតាមកិច្ចសន្យា ។

**ប្រការ២** ៖ លោក EWE SWEE KHENG ត្រូវទូទាត់បំណុលថ្លៃឈ្នួលទីតាំងរោងចក្រយន្តសាស្ត្រទី៦ ត្រឹមត្រីមាសទី១ ឆ្នាំ២០០២ ដែលមានទឹកប្រាក់សរុបចំនួន ២៣៥.០០០$ (ពីររយសាមសិបប្រាំពាន់) ដុល្លាអាមេរិក និងប្រាក់ពិន័យចំនួន ៥៣៤.១៣០$ (ប្រាំរយសាមសិបបួនពាន់មួយរយសាមសិប) ដុល្លាអាមេរិកជូនរដ្ឋក្នុងរយៈពេល៣០ថ្ងៃជាកំហិត គិតចាប់ពីថ្ងៃដែលបានចេញប្រកាសរំលាយចោលកិច្ចសន្យា និងដកហូតទីតាំងរោងចក្រយន្តសាស្ត្រទី៦ជាផ្លូវការ ។

**ប្រការ៣** ៖ កិច្ចសន្យាជួលរោងចក្រយន្តសាស្ត្រទី៦ចុះថ្ងៃទី១៤ ខែតុលា ឆ្នាំ១៩៩៤ និងលិខិតបទដ្ឋានដទៃទៀតដែលមានការពាក់ព័ន្ធនឹងការជួលនិងប្រគល់ទីតាំងរោងចក្រយន្តសាស្ត្រទី៦ត្រូវចាត់ទុកជានិរាករណ៍ ។

**ប្រការ៤** ៖ នាយកដ្ឋាន ទ្រព្យសម្បត្តិរដ្ឋនៃក្រសួងសេដ្ឋកិច្ច និង ហិរញ្ញវត្ថុ អគ្គាធិការនៃអគ្គាធិការដ្ឋាន ប្រធាននាយកដ្ឋានគណនេយ្យ ហិរញ្ញវត្ថុនៃក្រសួងឧស្សាហកម្ម រ៉ែនិងថាមពល និងលោក EWE SWEE KHENG មានភារកិច្ចអនុវត្តក្នុងក្របខ័ណ្ឌនៃសមត្ថកិច្ចរៀង១ខ្លួនតាមប្រកាសនេះ ។

**ប្រការ៥** ៖ ប្រកាសអន្តរក្រសួងនេះមានប្រសិទ្ធិភាពអនុវត្តជាតតិយុត្តិចាប់ពីថ្ងៃចុះហត្ថលេខានេះតទៅ ។

រាជធានីភ្នំពេញ,ថ្ងៃទី ខែ ឆ្នាំ២០០២

**ទេសរដ្ឋមន្ត្រី**
**រដ្ឋមន្ត្រីក្រសួងសេដ្ឋកិច្ច និង ហិរញ្ញវត្ថុ**

**គាត ឈន់**

**រដ្ឋមន្ត្រី**
**ក្រសួងឧស្សាហកម្ម រ៉ែនិងថាមពល**

**ចំលងជូន**

- ទីស្តីការគណៈរដ្ឋមន្ត្រី
- ក្រុមប្រឹក្សាអភិវឌ្ឍន៍កម្ពុជា
- ធនាគារជាតិនៃកម្ពុជា "នាយកដ្ឋានប្រតិបត្តិការ"
- ខុទ្ទកាល័យសម្តេចនាយករដ្ឋមន្ត្រី
- សាលាក្រុងភ្នំពេញ
- សាលាខ័ណ្ឌឫស្សីកែវ
- ដូចប្រការ ៤ "ដើម្បីអនុវត្ត"
- ឯកសារ

**ព្រះរាជាណាចក្រកម្ពុជា**
**ជាតិ សាសនា ព្រះមហាក្សត្រ**

**ក្រសួងសេដ្ឋកិច្ច និង ហិរញ្ញវត្ថុ**
**សាលាក្រុងភ្នំពេញ**
**លេខ :** ៤១៥ សហវ.

ភ្នំពេញ ថ្ងៃទី ០៤ ខែ កក្កដា ឆ្នាំ ២០០២

# ប្រកាស
## របស់ក្រសួងសេដ្ឋកិច្ច និង ហិរញ្ញវត្ថុ
## និងសាលាក្រុងភ្នំពេញ
## ស្តីពី
## ការលប់ចោលកិច្ចសន្យាជួលអតីតទីតាំងរោងភាពយន្តខេមរៈ

❋❋❋❋❋❋❋❋❋❋

-បានឃើញរដ្ឋធម្មនុញ្ញនៃព្រះរាជាណាចក្រកម្ពុជាឆ្នាំ១៩៩៣

-បានឃើញព្រះរាជក្រឹត្យលេខ នស/រ.ក.ត/១១៩៨/៧២ ចុះថ្ងៃទី៣០ ខែវិច្ឆិកា ឆ្នាំ១៩៩៨ ស្តីពីការតែងតាំងរាជរដ្ឋាភិបាលនៃព្រះរាជាណាចក្រកម្ពុជា

-បានឃើញច្បាប់ស្តីពីហិរញ្ញវត្ថុសំរាប់ការគ្រប់គ្រងឆ្នាំ២០០០ដែលប្រកាសឱ្យប្រើដោយព្រះរាជក្រមលេខនស/រកម/១២៩៩/១៥ ចុះថ្ងៃទី២៥ ខែធ្នូ ឆ្នាំ១៩៩៩

-បានឃើញអនុក្រឹត្យលេខ០៤/អនក្រ/បក ចុះថ្ងៃទី២០ ខែមករាឆ្នាំ២០០០ ស្តីពីការរៀបចំ និងការប្រព្រឹត្តិទៅនៃក្រសួងសេដ្ឋកិច្ច និង ហិរញ្ញវត្ថុ

-បានឃើញព្រះរាជក្រឹត្យ លេខ នស/រកត/១១៩៩/១៩១ ចុះថ្ងៃទី០៧ ខែវិច្ឆិកា ឆ្នាំ១៩៩៩ ស្តីពីការតែងតាំងប្រតិភូរាជរដ្ឋាភិបាល ទទួលបន្ទុកអភិបាលរាជធានីភ្នំពេញ

-យោងកិច្ចសន្យាបន្ថែមចុះថ្ងៃទី០៦ ខែតុលា ឆ្នាំ១៩៩៣ លើកិច្ចសន្យាស្តីពីការជួលអតីតទីតាំងរោងភាពយន្តខេមរៈ ចុះថ្ងៃទី០៤ ខែវិច្ឆិកា ឆ្នាំ១៩៩២

-យោងលិខិតលេខ ៦៩០ សហវ.ទរ ចុះថ្ងៃទី០៤ ខែមីនា ឆ្នាំ២០០២ របស់ក្រសួងសេដ្ឋកិច្ច និងហិរញ្ញវត្ថុ

## <u>សំរេច</u> :

**ប្រការ១** : លប់ចោលកិច្ចសន្យាស្តីពីការជួលអតីតទីតាំងរោងភាពយន្តខេមរៈ ចុះថ្ងៃទី០៤ ខែវិច្ឆិកា ឆ្នាំ១៩៩២ និងដកហូតអតីតទីតាំងរោងភាពយន្តខេមរៈដែលមានអាស័យដ្ឋានស្ថិតនៅតាមដងវិថី ហ្សាលដឺហ្គោល ក្នុងសង្កាត់ អូរឫស្សីទី៤ ខ័ណ្ឌ៧មករា ពីលោក យ៉ាន់ ទានយ៉ាន់ ដោយមូលហេតុមិនគោរពតាមកិច្ចសន្យា ។

**ប្រការ២** : លោក យ៉ាន់ ទានយ៉ាន់ ត្រូវទូទាត់បំណុលថ្លៃឈ្នួលអតីតទីតាំងរោងភាពយន្តខេមរៈ ត្រឹមខែមីនា ឆ្នាំ២០០២ ដែលមានទឹកប្រាក់សរុបចំនួន ៣៣.០០០$ (សាមសិបបីពាន់) ដុល្លាអាមេរិក និងប្រាក់ពិន័យចំនួន ៨.២៥០$ (ប្រាំបីពាន់ពីរយហាសិប) ដុល្លាអាមេរិកជូនរដ្ឋក្នុងរយៈពេល ៣០ថ្ងៃ ជាកំហិត គិតចាប់ពីថ្ងៃដែលបានចេញប្រកាសលប់ចោលកិច្ចសន្យា និងដកហូតអតីតទីតាំងរោងភាពយន្តខេមរៈ ជាផ្លូវការ ។

**ប្រការ៣** : កិច្ចសន្យាស្តីពីការជួលអតីតទីតាំងរោងភាពយន្តខេមរៈ ចុះថ្ងៃទី០៤ ខែវិច្ឆិកា ឆ្នាំ១៩៩២ និង លិខិតបទដ្ឋានដទៃទៀត ដែលមានការពាក់ព័ន្ធនឹងការជួល និង ប្រគល់អតីតទីតាំងរោងភាពយន្តខេមរៈត្រូវចាត់ទុកជានិរាករណ៍ ។

**ប្រការ៤** : នាយកដ្ឋាន ទ្រព្យសម្បត្តិរដ្ឋនៃក្រសួងសេដ្ឋកិច្ចនិងហិរញ្ញវត្ថុ មន្ទីរសេដ្ឋកិច្ចនិងហិរញ្ញវត្ថុ និង ការិយាល័យវិនិយោគ រាជធានីភ្នំពេញ និង លោក យ៉ាន់ ទានយ៉ាន់ មានភារកិច្ចអនុវត្តក្នុងក្របខ័ណ្ឌនៃសមត្ថកិច្ចរៀងៗខ្លួនតាមប្រកាសនេះ ។

**ប្រការ៥** : ប្រកាសអន្តរក្រសួង ស្ថាប័ននេះមានប្រសិទ្ធិភាពអនុវត្តជាគតិយុត្តិចាប់ពីថ្ងៃចុះហត្ថលេខានេះតទៅ ។

រាជធានីភ្នំពេញ,ថ្ងៃទី ខែ ឆ្នាំ២០០២

**ទេសរដ្ឋមន្ត្រី**

**រដ្ឋមន្ត្រី ក្រសួងសេដ្ឋកិច្ច និង ហិរញ្ញវត្ថុ** **ប្រតិភូរាជរដ្ឋាភិបាលទទួលបន្ទុកអភិបាលរាជធានីភ្នំពេញ**

**គាត ឈន់**

**ចំលងជូន**

-ទីស្តីការគណៈរដ្ឋមន្ត្រី

-ក្រុមប្រឹក្សាអភិវឌ្ឍន៍កម្ពុជា

-ធនាគារជាតិនៃកម្ពុជា "នាយកដ្ឋានប្រតិបត្តិការ"

-សាលាខ័ណ្ឌ៧មករា

-ដូចប្រការ០៤ "ដើម្បីអនុវត្ត"

-ឯកសារ

psoplul /Prakas on contract termination of M Industry (left)

**ព្រះរាជាណាចក្រកម្ពុជា**

**ជាតិ សាសនា ព្រះមហាក្សត្រ**

ក្រសួងសេដ្ឋកិច្ច និង ហិរញ្ញវត្ថុ

លេខ ០១៥ សហវ.៣៨

រាជធានីភ្នំពេញ,ថ្ងៃទី ០៣ ខែកក្កដា ឆ្នាំ២០០៧

# សេចក្ដីជូនដំណឹង

## ស្ដីពី
## ការអនុវត្តន៍ប្រមូលពន្ធលើ
## មធ្យោបាយដឹកជញ្ជូននិងយានជំនិះគ្រប់ប្រភេទសំរាប់ឆ្នាំ ២០០២

ក្រសួងសេដ្ឋកិច្ចនិងហិរញ្ញវត្ថុមានកិត្តិយសសូមជំរាបលោក-លោកស្រីដែលជាម្ចាស់យានយន្តគ្រប់ប្រភេទមេត្តាជ្រាបថា : ចាប់តាំងពីក្រសួងសេដ្ឋកិច្ចនិងហិរញ្ញវត្ថុបាន ចេញប្រកាស លេខ ៣៤៩ សហវ.ពដ ចុះថ្ងៃទី០៩ ខែ ឧសភា ឆ្នាំ២០០៧ និងសេចក្តីជូនដំណឹងលេខ ០១៧ សហវ.ពដ ចុះថ្ងៃទី ០៩ ខែឧសភា ឆ្នាំ២០០៧ ស្តីពីការប្រមូលពន្ធលើមធ្យោបាយដឹកជញ្ជូននិងយានជំនិះគ្រប់ប្រភេទសំរាប់ឆ្នាំ២០០៧ លោក-លោកស្រីជាម្ចាស់យានយន្តគ្រប់ប្រភេទមួយចំនួន ប្រកបដោយស្មារតីភ្ញាក់រលឹកយកចិត្តទុកដាក់គោរពកាតព្វកិច្ចបង់ពន្ធ យ៉ាងច្រើនកុះករជាបន្តបន្ទាប់ ។

ជាថ្មីម្តងទៀត ក្រសួងសេដ្ឋកិច្ចនិងហិរញ្ញវត្ថុសូមជំរាបជូនលោក-លោកស្រី ជាម្ចាស់យានយន្តគ្រប់ប្រភេទជ្រាបថា : ការបង់ពន្ធលើមធ្យោបាយដឹកជញ្ជូន និងយានជំនិះគ្រប់ប្រភេទសំរាប់ឆ្នាំ២០០៧ គឺត្រូវចាប់អនុវត្តពីថ្ងៃទី ១៥ ខែ ឧសភា ឆ្នាំ២០០៧ រហូតដល់ថ្ងៃទី ១៥ ខែ សីហា ឆ្នាំ២០០៧ ដោយម្ចាស់យានយន្តនិមួយៗ ត្រូវបំពេញលិខិតប្រកាសចំនួន ០២សន្លឹក តាមគំរូឯកភាពរបស់នាយកដ្ឋានពន្ធដារ ។ លិខិតប្រកាសនេះមានតំលៃ **មួយសន្លឹក ២០០រៀល** ។ ចំណូលពីការលក់លិខិតប្រកាស ត្រូវបង់ចូលថវិការដ្ឋ ។

ចាប់ពីថ្ងៃទី ១៦ ខែ សីហា ឆ្នាំ២០០៧តទៅ នឹងត្រូវអនុវត្តការផាកពិន័យតាមច្បាប់ជាធរមាន ។

ក្រសួងសេដ្ឋកិច្ច និង ហិរញ្ញវត្ថុ មានសង្ឃឹម និង ជឿជាក់លើស្មារតីយកចិត្តទុកដាក់ក្នុងការបំពេញកាតព្វកិច្ចសារពើពន្ធរបស់ប្រជាពលរដ្ឋគ្រប់ៗរូប ។

**ទេសរដ្ឋមន្ត្រី**
**រដ្ឋមន្ត្រីក្រសួងសេដ្ឋកិច្ច និង ហិរញ្ញវត្ថុ**

**គាត ឈន់**

**ចម្លងជូនៈ**

- ទីស្តីការគណៈរដ្ឋមន្ត្រី
- គ្រប់សាលាខេត្ត-ក្រុង
  "ដើម្បីជ្រាបជាពត៏មាន"
- គ្រប់សាខាពន្ធដារគ្រប់ខេត្ត-ក្រុង
- ឯកសារ.កាលប្បវត្តិ

ព្រះរាជាណាចក្រកម្ពុជា
ជាតិ សាសនា ព្រះមហាក្សត្រ

ក្រសួងសាធារណការ និង ដឹកជញ្ជូន

លេខ : 220 ស.ស/ក សក

រាជធានីភ្នំពេញ.ថ្ងៃទី ០៣ ខែ ៧ ឆ្នាំ២០០២

# សេចក្តីសំរេច

## ស្តីពីការបង្កើតក្រុមការងារសហប្រតិបត្តការអភិវឌ្ឍន៍តំបន់ត្រីកោណ កម្ពុជា-ឡាវ-វៀត-ណាម និង កម្ពុជា-ឡាវ-ថៃ

---

## រដ្ឋមន្ត្រីក្រសួងសាធារណការ និង ដឹកជញ្ជូន

-បានឃើញ រដ្ឋធម្មនុញ្ញ នៃ ព្រះរាជាណាចក្រកម្ពុជា

-បានឃើញ ព្រះរាជក្រឹត្យ លេខ នស/រកត/១១៩៨/៧២ ចុះថ្ងៃទី ៣០.១១.១៩៩៨ ស្តីពីការតែងតាំងរាជរដ្ឋាភិបាលកម្ពុជា។

-បានឃើញ ព្រះរាជក្រមលេខ ០៦/នស/៩៤ ចុះថ្ងៃទី ៣០.១១.១៩៩៤ ស្តីពីសហលក្ខន្តិកៈមន្ត្រី-រាជការស៊ីវិល។

-បានឃើញ ព្រះរាជក្រមលេខ នស/រកម/០១៩៦/០៣ ចុះថ្ងៃទី ២៤ខែមករា ឆ្នាំ ១៩៩៦ ស្តីពីការបង្កើតក្រសួងសាធារណការ និង ដឹកជញ្ជូន។

-បានឃើញ អនុក្រឹត្យលេខ ១៤ អនក្រ.បក ចុះថ្ងៃទី ០៣ ខែមិនា ឆ្នាំ ១៩៩៨ ស្តីពីការរៀបចំ និងការប្រព្រឹត្តទៅរបស់ក្រសួងសាធារណការ និង ដឹកជញ្ជូន។

-បានឃើញ សេចក្តីជូនដំណឹងលេខ ៦៣៥ សជណ.សរ ចុះថ្ងៃទី ២៥.០៤.២០០២ របស់ទីស្តីការគណរដ្ឋមន្ត្រី។

-យោងតាមការចាំបាច់របស់ក្រសួង។

## សំរេច

**ប្រការ ១:** បង្កើតឡើងនូវក្រុមការងារសហប្រតិបត្តការអភិវឌ្ឍន៍តំបន់ត្រីកោណ កម្ពុជា-ឡាវ-វៀតណាម និង កម្ពុជា-ឡាវ-ថៃ ដូចមានសមាសភាពខាងក្រោម:

| | | |
|---|---|---|
| ១-ឯកឧត្តម **ឈិន គង់ហ៊ាន** | អគ្គនាយកសាធារណការ | ប្រធាន |
| ២-លោក **ថង ពិសិដ្ឋ** | អគ្គនាយករងសាធារណការ | អនុប្រធាន |
| ៣-លោក **ម៉ា ស៊ឹម សុរិយា** | នាយក នាយកដ្ឋានផែនការ | សមាជិកសំរបសំរួលអចិន្ត្រៃយ៍ |
| ៤-លោក **លឹម ស៊ីដេនីន** | នាយក នាយកដ្ឋានផ្លូវថ្នល់ | សមាជិក |
| ៥-លោក **គីម បូរី** | នាយករង មជ្ឈមណ្ឌលស្រាវជ្រាវបច្ចេកទេសសាធារណការ | សមាជិក |
| ៦-លោក **ផែង សុទិដ្ឋារ៉ោ** | នាយក នាយកដ្ឋានផ្លូវអាកាស | សមាជិក |
| ៧-លោក **យូ រ៉ា** | មន្ត្រីការិយាល័យអាស៊ាននាយកដ្ឋានផែនការ | សមាជិក |
| ៨-លោក **សួង ពិសិដ្ឋ** | នាយកមន្ទីរសាធារណការ និងដឹកជញ្ជូនខេត្តរតនៈគីរី | សមាជិក |
| ៩-លោក **ហ៊ីង ផាន់ស៊ឿន** | នាយកមន្ទីរសាធារណការ និងដឹកជញ្ជូនខេត្តស្ទឹងត្រែង | សមាជិក |
| ១០-លោក **ផាន់ សំអាន** | នាយកមន្ទីរសាធារណការ និងដឹកជញ្ជូនខេត្តព្រះវិហារ | សមាជិក |

**ប្រការ ២:** ក្រុមការងារមានភារៈកិច្ចៈ

-ចូលរួមកិច្ចប្រជុំពិភាក្សាការងារ គណៈកម្មការសហប្រត្តិការអភិវឌ្ឍន៍តំបន់ត្រីកោណលើវិស័យហេដ្ឋារចនាសម្ព័ន្ធដឹកជញ្ជូន

-ចូលរួមសិក្សាស្រាវជ្រាវរៀបចំផែនការ ទិសដៅយុទ្ធសាស្ត្រ និងអនុវត្តគំរោងការអភិវឌ្ឍន៍ ហេដ្ឋារចនាសម្ព័ន្ធដឹកជញ្ជូន ក្នុងក្របខ័ណ្ឌតំបន់ត្រីកោណ

-សំរបសំរួលការងារជាមួយក្រសួង ស្ថាប័ន និង អាជ្ញាធរពាក់ព័ន្ធ ក្នុងក្រមការអភិវឌ្ឍន៍ ហេដ្ឋារចនាសម្ព័ន្ធដឹកជញ្ជូន ក្នុងតំបន់ត្រីកោណ

-បំពេញភារៈកិច្ចផ្សេងទៀតដែលគណៈកម្មការ និងក្រសួងប្រគល់អោយ

-ធ្វើរបាយការបូកសរុបលទ្ធផលការងារខាងលើ ជូនគណៈកម្មការ ជូនក្រសួង និងស្ថាប័ន ពាក់ព័ន្ធ

**ប្រការ ៣:** អគ្គនាយកសាធារណការ, នាយក មជ្ឈមណ្ឌលស្រាវជ្រាវបច្ចេកទេសសាធារណការ, នាយកនៃ នាយកដ្ឋានផែនការ នាយក នៃនាយកដ្ឋានផ្លូវថ្នល់ នាយកខុទ្ទកាល័យ នាយកមន្ទីរសាធារណការ និងដឹកជញ្ជូនខេត្ត រតនគីរី, ស្ទឹងត្រែង, ព្រះវិហារ ព្រមទាំងសាមីខ្លួនត្រូវទទួលបន្ទុក អនុវត្តតាមខ្លឹមសារនៃប្រកាស អោយមានប្រសិទ្ធភាពចាប់ពីថ្ងៃចុះហត្ថលេខាតទៅ។

រដ្ឋមន្ត្រី

ចម ប្រសិទ្ធ

**ចំឡងជូនៈ**

-ទីស្តីការគណៈរដ្ឋមន្ត្រី

-ដូចមាត្រា៣

-ក្រសួងពាណិជ្ជកម្ម

-ក្រសួងការបរទេស

-ក្រសួងសេដ្ឋកិច្ច និង ហិរញ្ញវត្ថុ

-ឯកឧត្តមរដ្ឋលេខាធិការ

-ឯកឧត្តមអនុរដ្ឋលេខាធិការ

-ឯកឧត្តមអគ្គនាយក

-នាយកដ្ឋានបុគ្គលិកធនធានមនុស្ស

-សាមីខ្លួន " ដើម្បីអនុវត្ត"

-ឯកសារ-កាលប្បវត្តិ

ព្រះរាជាណាចក្រកម្ពុជា
ជាតិ សាសនា ព្រះមហាក្សត្រ

សក
MOSALVY

ក្រសួងសង្គមកិច្ច ការងារ បណ្តុះបណ្តាលវិជ្ជាជីវៈ
និងយុវនីតិសម្បទា

លេខ : ១៧ សកបយ.

រាជធានីភ្នំពេញ,ថ្ងៃទី ០៥ ខែកក្កដា ឆ្នាំ២០០២

## ស ា រ ា ច រ

## ស្តីពី

## ការដោះស្រាយវិវាទការងារ

ក្រសួងសង្គមកិច្ច ការងារ បណ្តុះបណ្តាលវិជ្ជាជីវៈ និងយុវនីតិសម្បទា សូមជំរាបលោក លោកស្រីជាម្ចាស់ និងជានាយកសហគ្រាស គ្រឹះស្ថាន បងប្អូនកម្មករនិយោជិត និងអង្គការវិជ្ជាជីវៈនានា ដែលស្ថិតនៅក្នុងដែនអនុវត្តនៃច្បាប់ស្តីពីការងារ ហើយមានទីតាំងធ្វើការងារនៅក្នុងរាជធានីភ្នំពេញបានជ្រាបថា ចាប់ពីពេលនេះតទៅនៅពេលមានវិវាទការងារកើតឡើងទាំងវិវាទការងាររួម ទាំងវិវាទបុគ្គល សូមអស់លោក លោកស្រីជូនដំណឹងឬដាក់ពាក្យបណ្តឹងទៅប៉ុស្តិ៍អធិការកិច្ចការងារនៅតាមខ័ណ្ឌដែលសហគ្រាស គ្រឹះស្ថានរបស់ខ្លួនស្ថិតនៅ ដើម្បីមន្ត្រីអធិការកិច្ចការងារនៅតាមប៉ុស្តិ៍ពិនិត្យ និងដោះស្រាយវិវាទការងារនោះបានឆាប់រហ័សជាង ។ ប៉ុស្តិ៍អធិការកិច្ចការងារទាំងនោះមានអាសយដ្ឋាន ដូចមាននៅក្នុងឧបសម្ព័ន្ធជូនជាប់ជាមួយ ។

ក្រសួងសង្គមកិច្ច ការងារ បណ្តុះបណ្តាលវិជ្ជាជីវៈ និងយុវនីតិសម្បទា មានសេចក្តីសង្ឃឹមយ៉ាងមុតមាំថា អស់លោក លោកស្រីជាម្ចាស់ និងជានាយកសហគ្រាស គ្រឹះស្ថាន បងប្អូនកម្មករនិយោជិត អង្គការវិជ្ជាជីវៈដែលស្ថិតនៅក្នុងខ័ណ្ឌសីមានៃរាជធានីភ្នំពេញច្បាស់ជាយកចិត្តទុកដាក់អនុវត្តតាមខ្លឹមសារខាងលើបានល្អប្រសើរពុំខាន ។

**ចម្លងជូន**

- ក្រសួងព្រះបរមរាជវាំង
- អគ្គលេខាធិការដ្ឋានព្រឹទ្ធសភា
- អគ្គលេខាធិការដ្ឋានរដ្ឋសភា
- ខុទ្ទកាល័យសម្តេចនាយករដ្ឋមន្ត្រី
- ទីស្តីការគណៈរដ្ឋមន្ត្រី
- គ្រប់ក្រសួងពាក់ព័ន្ធ
- សាលាក្រុងភ្នំពេញ

"ដើម្បីជូនជ្រាប"

- អគ្គនាយកដ្ឋាន ការងារ និងបណ្តុះបណ្តាលវិជ្ជាជីវៈ
- អគ្គនាយកដ្ឋានកិច្ចការរដ្ឋបាល និងហិរញ្ញវត្ថុ
- គ្រប់មន្ទីរសង្គមកិច្ច ការងារ បណ្តុះបណ្តាលវិជ្ជាជីវៈ និងយុវនីតិសម្បទា ខេត្ត-ក្រុង

"ដើម្បីផ្សព្វផ្សាយ និងអនុវត្ត"

- សមាគមនិយោជក
- សហព័ន្ធសហជីព

"ដើម្បីជ្រាប"

- គ្រប់បណ្តាញវិទ្យុ និងទូរទស្សន៍ "ដើម្បីជួយផ្សព្វផ្សាយ"

រដ្ឋមន្ត្រី
ក្រសួងសង្គមកិច្ច ការងារ បណ្តុះបណ្តាលវិជ្ជាជីវៈ និងយុវនីតិសម្បទា

អ៊ិត សំហេង

**ឧបសម្ព័ន្ធនៃសារាចរ**

លេខ: ១៧ សកបយ. ចុះថ្ងៃទី០៥ ខែកក្កដា ឆ្នាំ២០០២

ស្តីពីការដោះស្រាយវិវាទការងារ

**អាសយដ្ឋានប៉ុស្តិ៍អធិការកិច្ចការងារតាមខណ្ឌនៅរាជធានីភ្នំពេញ**

១-ប៉ុស្តិ៍អធិការកិច្ចការងារខណ្ឌឫស្សីកែវ: នៅសាលាខណ្ឌមានជ័យ ផ្ទះលេខ ០៣ , ផ្លូវលេខ៣៦១, ភូមិព្រែក សង្កាត់ច្បារអំពៅទី១ លេខទូរស័ព្ទទំនាក់ទំនង ០១៦. ៨៨៥ ០០៥- ០១២ .៨៤៥ ២១៤ ។

២-ប៉ុស្តិ៍អធិការកិច្ចការងារខណ្ឌចំការមន: នៅសាលាខណ្ឌចំការមន ផ្ទះលេខ១៦៩, ផ្លូវម៉ៅសេទុង, ភូមិ១ សង្កាត់បឹងកេងកងទី៣ លេខទូរស័ព្ទទំនាក់ទំនង ០១២. ៨៧២ ៥៦៥- ០១២. ៨៣៦ ១០៥ ។

៣-ប៉ុស្តិ៍អធិការកិច្ចការងារខណ្ឌដង្កោ: នៅនាយកដ្ឋានអធិការកិច្ចការងារនៃក្រសួងសង្គមកិច្ច ការងារ បណ្តុះបណ្តាលវិជ្ជាជីវៈ និងយុវនីតិសម្បទា អគារលេខ ២៨ ផ្លូវលេខ ១៨៤ សង្កាត់ជ័យជំនះ ខណ្ឌដូនពេញ លេខទូរស័ព្ទទំនាក់ទំនង ០១២. ៩៤៥ ០៥៥- ០១១. ៨៧៣ ៧៨៧ ។

៤-ប៉ុស្តិ៍អធិការកិច្ចការងារខណ្ឌឫស្សីកែវ: នៅនាយកដ្ឋានអធិការកិច្ចការងារនៃក្រសួងសង្គមកិច្ច ការងារ បណ្តុះបណ្តាលវិជ្ជាជីវៈ និងយុវនីតិសម្បទា អគារលេខ ២៨ ផ្លូវលេខ ១៨៤ សង្កាត់ជ័យជំនះ ខណ្ឌដូនពេញ លេខទូរស័ព្ទទំនាក់ទំនង ០១៦. ៨៨០ ២០៩- ០១១. ៩៧៣ ២៩៥ ។

៥-ប៉ុស្តិ៍អធិការកិច្ចការងារខណ្ឌទួលគោក: នៅនាយកដ្ឋានអធិការកិច្ចការងារនៃក្រសួងសង្គមកិច្ច ការងារ បណ្តុះបណ្តាលវិជ្ជាជីវៈ និងយុវនីតិសម្បទា អគារលេខ ២៨ ផ្លូវលេខ ១៨៤ សង្កាត់ជ័យជំនះ ខណ្ឌដូនពេញ លេខទូរស័ព្ទទំនាក់ទំនង ០១២. ៩២០ ៤៤៩- ០១១. ៨៧២ ៩៧២ ។

៦-ប៉ុស្តិ៍អធិការកិច្ចការងារខណ្ឌដូនពេញ: នៅនាយកដ្ឋានអធិការកិច្ចការងារនៃក្រសួងសង្គមកិច្ច ការងារ បណ្តុះបណ្តាលវិជ្ជាជីវៈ និងយុវនីតិសម្បទា អគារលេខ ២៨ ផ្លូវលេខ ១៨៤ សង្កាត់ជ័យជំនះ ខណ្ឌដូនពេញ លេខទូរស័ព្ទទំនាក់ទំនង ០១២. ៨៦៨ ៣៧៧ ។

៧-ប៉ុស្តិ៍អធិការកិច្ចការងារខណ្ឌ៧ មករា: នៅនាយកដ្ឋានអធិការកិច្ចការងារនៃក្រសួងសង្គមកិច្ច ការងារ បណ្តុះបណ្តាលវិជ្ជាជីវៈ និងយុវនីតិសម្បទា អគារលេខ ២៨ ផ្លូវលេខ ១៨៤ សង្កាត់ជ័យជំនះ ខណ្ឌដូនពេញ លេខទូរស័ព្ទទំនាក់ទំនង ០១៦. ៨៩៧ ៩៣៥ ។